# مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ ហ្វីក្ហោះហ្អ៍ ថ្នាក់ទី ៥

(អាយុ ៩-១០ ឆ្នាំ)

រ៉ស្វូលុលឡោះហ្អ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជា ជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - អធិប្បាយ ១ ....................................... ៥

មេរៀនទី ២ - អធិប្បាយ ២ ....................................... ១០

មេរៀនទី ៣ - អធិប្បាយ ៣ ....................................... ១៤

មេរៀនទី ៤ - អ៊ូស្វ៊ូល អ៊ុដ្ឌឌីន ....................................... ១៧

មេរៀនទី ៥ - សន្ទនាខ្លីៗអំពី អ៊ូស្វ៊ូល អ៊ុដ្ឌឌីន ១ ........... ២១

មេរៀនទី ៦ - សន្ទនាខ្លីៗអំពី អ៊ូស្វ៊ូល អ៊ុដ្ឌឌីន ២ .......... ២៧

មេរៀនទី ៧ - ហ្វ៊ូរូអ៊ុដ្ឌឌីន ១ ....................................... ៣១

មេរៀនទី ៨ - ហ្វ៊ូរូអ៊ុដ្ឌឌីន ២ ....................................... ៣៦

មេរៀនទី ៩ - វូឌុអ៊ុ (وُضُوء) ....................................... ៤០

មេរៀនទី ១០ - អាស្វាន និង អ៊ីក៏ម៉ាស់ ....................................... ៤៦

មេរៀនទី ១១ - ស្ហ៏ឡាត់ ....................................... ៥៤

មេរៀនទី ១២ - ការរៀបចំខ្លួនបំពេញស្ហ៏ឡាត់ ............. ៥៧

មេរៀនទី ១៣ - សំលៀកបំពាក់ស្ហ៏ឡាត់ ....................... ៦០

មេរៀនទី ១៤ - កន្លែងបំពេញស្ហ៏ឡាត់ ....................... ៦៤

មេរៀនទី ១៥ - ពេលស្ហ៏ឡាត់ ....................................... ៦៧

មេរៀនទី ១៦ - ណាយ៉ាសាស់ (نجسة) ........................... ៧០

មេរៀនទី ១៧ - តាក់លីដ្វ ....................................... ៧៤

មេរៀនទី ១៨ - សាឡើងវិញ ....................................... ៧៧

មេរៀនទី ១៩ - ទង្វើរ៉ាយ៉ីបក្នុងស្ហ៏ឡាត់ ........................ ៨៥

ទង្វើម៉ាក់រ៉ុះហ៍ ជាឧទាហរណ៍ មានដូចជា ៖

និយាយដោយប្រើសម្តីធំ ជក់បារី ដេកច្រើន ជាដើម ។

**មូបាស់** (مباح)

ទង្វើមូបាស់គឺទង្វើដែលគេអនុញ្ញាតឲ្យធ្វើ ។ ទោះធ្វើទង្វើនោះក្តី មិនធ្វើទង្វើនោះក្តី នឹងមិនមានរង្វាន់ ហើយក៏មិនមានបាបទេដែរ ។ មានពាក្យមួយទៀតមានន័យដូចមូបាស់ដែរ គឺពាក្យថា យ៉ាអ៊ីស (جائز) ដែលមានន័យថាអនុញ្ញាត ។ ក៏ប៉ុន្តែគេអាច ទទួលបាននូវរង្វាន់បើគេធ្វើដើម្បីអល់ឡោះហ៍ ﷻ ។ ឧទាហរណ៍ ៖ យើងគប្បីថា "ប៊ីសមិលឡាហ៍" មុនហូបបាយ ។

ទង្វើមូបាស់ ជាឧទារណ៍ មានដូចជា ៖
ហូប ផឹក ធ្វើកីឡា ជាដើម ។



**មេរៀនទី ១**

# អធិប្បាយ ១

**វ៉ាយិប** (وجب)

វ៉ាយិបមានន័យថាចាំបាច់ ។ បើសិនជាអ្វីមួយជាវ៉ាយិប យើងត្រូវតែធ្វើជាចាំបាច់ ព្រោះអល់ឡោះហ៍ឲ្យយើងធ្វើ ។ អល់ឡោះហ៍បានប្រោសប្រណីយើងច្រើនណាស់ ។ ដើម្បីមិនភ្លេចព្រះគុណព្រះអង្គ ពេលណាព្រះអង្គឲ្យយើងធ្វើអ្វីមួយ យើងត្រូវតែធ្វើតាមព្រះអង្គ ។

បើយើងធ្វើទង្វើវ៉ាយិប យើងនឹងបានទទួលរង្វាន់ (ស្វាវ៉ាប់) ពីអល់ឡោះហ៍ ។ បើយើងមិនធ្វើទង្វើវ៉ាយិបនោះទេ វាជាអំពើបាបមួយ ហើយយើងនឹងត្រូវទទួលទណ្ឌកម្មពីអល់ឡោះហ៍ ។

ឧទាហរណ៍ ទង្វើវ៉ាយិបមាន ៖
ស្វ៍ឡាត្ត (ការធ្វើនមស្ការបូជាអល់ឡោះហ៍) ស្វៅម៍ (កាន់

សីលត្រណមអាហារ) ស្ញាកាត្ត់ (ដាក់ទាន) ។

## ស៊ូណាត់ (رنة)

ទង្វើស៊ូណាត់ជាទង្វើប្រសើរដែលគប្បីធ្វើ ព្រោះ អល់ឡោះហ្វ៍ទ្រង់សព្វព្រះហឫទ័យ ។ ក៏ប៉ុន្តែវាមិនមែនជាទង្វើវ៉ាយ៉ិបទេ ។ មានទង្វើស៊ូណាត់ច្រើនដែលព្រះសាស្តា صلى الله عليه وآله وسلم បានបង្ហាត់បង្រៀនយើង ។

ការពិត រាល់ពេលដែលព្រះសាស្តា صلى الله عليه وآله وسلم មានទម្លាប់ធ្វើអ្វីៗ យើងគប្បីធ្វើអ្វីនោះដែរព្រោះវាជាស៊ូណាត់ ។

បើយើងធ្វើទង្វើស៊ូណាត់ អល់ឡោះហ្វ៍﷿នឹងប្រទានរង្វាន់ (ស្វាវ៉ាប់) ឲ្យយើង តែបើយើងមិនធ្វើទេ នឹងមិនមានបាបទេ ។

ឧទាហរណ៍ទង្វើស៊ូណាត់ ៖
សូត្រព្រះគម្ពីរគួរអាន ទៅមើលអ្នកជម្ងឺ និងជួយជនក្រីក្រ ។

## ហ្ការ៉ាំ (حَرَام)



ហ្ការ៉ាំ មានន័យថា ហាម ។ បើអ្វីមួយត្រូវហាម យើងចាំបាច់មិនត្រូវធ្វើអ្វីនោះជាដាច់ខាត ពីព្រោះវានឹងធ្វើឲ្យ អល់ឡោះហ្វ៍﷿មិនសព្វព្រះហឫទ័យ ។ ពេលណាយើងធ្វើអំពើហ្ការ៉ាំ ពេលនោះយើងបានធ្វើអំពើបាប អល់ឡោះហ្វ៍﷿ នឹងធ្វើទណ្ឌកម្មយើង ។ បើយើងមិនធ្វើអំពើបាបទេ អល់ឡោះហ្វ៍﷿នឹងឲ្យរង្វាន់យើង ។

អំពើហ្ការ៉ាំ ជាឧទាហរណ៍ មានដូចជា ៖

ហូបសាច់ជ្រូក មិនស្តាប់ឪពុកម្តាយ និងនិយាយកុហក ជាដើម ។

## ម៉ាក់រុះហ្វ៍ (مكروه)

ទង្វើម៉ាក់រុះហ្វ៍គឺទង្វើដែល យកល្អ យើងគប្បីចៀសវាងធ្វើ ពីព្រោះវាមិនធ្វើឲ្យ អល់ឡោះហ្វ៍﷿ទ្រង់សព្វព្រះហឫទ័យទេ ។ ក៏ប៉ុន្តែវាមិនមែនទង្វើហ្ការ៉ាំទេ ។ បើយើងចៀសវាងមិនធ្វើទង្វើម៉ាក់រុះហ្វ៍ទេ អល់ឡោះហ្វ៍﷿នឹងឲ្យរង្វាន់យើង តែបើយើងធ្វើទង្វើនោះ យើងមិនបានធ្វើអំពើបាបទេ ។

## ស៊ាហ៊ីដ៍ (زهد)

គឺបុគ្គលដែលមិនស្ងួរចូលចិត្តវត្ថុរបស់របរនានា ក្នុងលោកនេះ ។ ប្រសិនបើគេបានទទួលអ្វីមួយប្រសើរ គេមិនរីករាយដល់ថ្នាក់ភ្លេចអល់ឡោះហ្វ័ﷻទេ ។ បើគេជួបប្រទះសេចក្តីអាក្រក់ អកុសល គេមិនរន្ធត់ដល់ថ្នាក់ភ្លេចអល់ឡោះហ្វ័ﷻទេ ។ គេពេញចិត្តចំពោះព្រះឆន្ទៈអល់ឡោះហ្វ័ﷻជានិច្ច ហើយមិនត្អូញត្អែរដាក់ព្រះអង្គﷻទេ ។ គេជាបុគ្គលដែលមានសេចក្តីសោមនស្ស ។

អល់ឡោះហ្វ័ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ៥៧ អាយ៉ាស់ ២៣) ថា ៖
*"ដើម្បីនឹងកុំឲ្យពួកអ្នកអស់សង្ឃឹមពីព្រោះអ្វីមួយ ដែលបានរបូតផុតពីពួកអ្នក និងដើម្បីនឹងកុំឲ្យពួកអ្នកសប្បាយរីករាយជ្រុលពេកនឹងអ្វីមួយ ដែលគេបានប្រទានឲ្យពួកអ្នក ។ អល់ឡោះហ្វ័ពុំសព្វព្រះហឫទ័យបុគ្គលណា ដែលព្រហើនមានអំនួតទេ ។"*

## មុតតាគ្គី (متقي)



## លំហាត់

ចូរឆ្លើយសំណួរ ថាទង្វើទាំងខាងក្រោមនេះជាទង្វើ ហ្វារ៉ុំ ស៊ូណាត់ ម៉ាក់រុះហ្វ៍ ឬ មូបាស់ ?

១ ពាក់ស្បែកជើងខ្មៅ ។ ____________
២ ហូប បឹកគឺ នៅឯហាងម៉ាក់ដូណាល់ដ៍ ។ ____________
៣ ងូតទឹកថ្ងៃសុក្រ ។ ________________
៤ ធ្វើដំណើរក្នុងខែរ៉ម៉ាដន ។ ________________
៥ ស្តាប់ឪពុកម្តាយ ។ ________________
៦ ធ្វើដំណើរក្នុងខែស្វ៊ហ្វារ ។ ________________
៧ នៅតែហូបពេលឆ្អែតហើយ ។ ________________
៨ ស្តាប់តន្ត្រី ។ ________________
៩ កាត់ក្រចកថ្ងៃព្រហស្បតិ៍ ។ ________________
១០ ធ្វើស្វ៊ឡាត់ក្នុងពេលកំណត់ ។ ________________

**មេរៀនទី ២**

# អធិប្បាយ ២

## មុស្លីម

មុស្លីមគឺអ្នកដែលចុះចូល ក្រោមព្រះឆន្ទៈអល់ឡោះហ្វ៍عزّ وجلّ ។ ពោលគឺអ្នកនោះមិនត្រូវប្រឆាំង គោលបំណងអល់ឡោះហ្វ៍عزّ وجلّទេ ។ មុស្លីមជឿព្រះតែមួយគត់ជឿព្រះសាស្តាទាំងឡាយعليهم السلامរបស់អល់ឡោះហ្វ៍عزّ وجلّ និងជឿថាមានថ្ងៃជំនុំជម្រះ ។ អ្នកណាដែលសូត្រកាលីម៉ាស្ហ៍ (كلمة) ដោយយល់ន័យ គេហៅអ្នកនោះថាមុស្លីម ។

របៀបសូត្រកាលីម៉ាស្ហ៍មានដូចតទៅគឺ ៖

*ឡា អ៊ីឡាហ្វា អ៊ីលឡុលឡោះហ្វ៍* មានន័យថា៖ មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍عزّ وجلّទេ ។
*មូហ៊ាំម៉ាដ្ហ៍ឌូរ រ៉ស៊ូលុលឡោះហ្វ៍* មានន័យថា៖ មូហ៊ាំម៉ាដ្ហ៍ជាព្រះសាស្តារបស់អល់ឡោះហ្វ៍ ។



អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ ៣ អាលី អ៊ីមរ៉ន អាយ៉ាស្ហ៍ ១០២) ថា៖
*"ឱបណ្តាអ្នកមានសទ្ធាអើយ ពួកអ្នកចូរខ្លាចក្រែងអល់ឡោះហ្វ៍ដោយការខ្លាចក្រែងពិតប្រាកដ ហើយចូរពួកអ្នកកុំស្លាប់ក្រៅភាពជាមុស្លិមឡើយ ។"*

## **មុមីន**(مؤمن)

មុមីនមានកម្រឹតខ្ពស់ជាងមុស្លីម ។ មុមីនជឿព្រះតែមួយ ជឿព្រះសាស្តាعليهم السلامទាំងឡាយរបស់អល់ឡោះហ្វ៍عزّ وجلّ និងជឿថ្ងៃជំនុំជម្រះដូចមុស្លីមដែរ ក៏ប៉ុន្តែគេជឿយុត្តិធម៌របស់អល់ឡោះហ្វ៍និងជឿអ៊ីម៉ាំទាំង ១២ عليهم السلام ។

អល់ឡោះហ្វ៍عزّ وجلّមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ ៤៩ អាល់-ហ៊ូយ្ជូរ៉ត់ អាយ៉ាស្ហ៍ ១៥) ថា៖
*"បណ្តាមុមីនគឺជនទាំងឡាយ ដែលមានសទ្ធាចំពោះអល់ឡោះហ្វ៍និងសាស្តាព្រះអង្គ បន្ទាប់មកពួកគេមិនសង្ស័យទេ ហើយពួកគេតស៊ូនៅលើមាគ៌ាអល់ឡោះហ្វ៍ដោយទ្រព្យនិងខ្លួន ។ ជនទាំងនោះជាអ្នកសច្ចៈ ។"*

## ហ្វាស៊ីក្ហ (فاسق)

អ្នកហ្វាស៊ីក្ហគឺអ្នក ដែលមិនស្តាប់បង្គាប់អល់ឡោះហ្ម៍﷿ ដោយចេតនា ។ អ្នកនេះធ្វើអំពើបាបដោយចេញមុខឲ្យអ្នកផងទាំងឡាយឃើញ ។ មនុស្សបែបនេះដែលហ៊ានប្រព្រឹត្តបំពានដាក់អល់ឡោះហ្ម៍﷿ចំពោះមុខអ្នកផងដទៃ ជាប្រភេទមនុស្សសាងបាបកម្មអាក្រក់បំផុត ហើយដើរតាមគន្លងមារស្ហៃតន ។

អល់ឡោះហ្ម៍﷿មានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ១៨ អាយ៉ាស់ ៥០) ថា ៖

*"កាលដែលយើងមានតម្រាស់ ចំពោះទេវតាទាំងឡាយថា៖ "ចូរអ្នកទាំងឡាយក្រាបប្រណិប័តន៍អាដាំ ។" ពួកគេ[ទាំងអស់]បានក្រាបប្រណិប័តន៍ លើកលែងតែអ៊ិបលិស (មារស្ហៃតន) ទេដែលជាម្នាក់ក្នុងចំណោមពួកជិនទាំងឡាយ ។ គេបានប្រព្រឹត្តល្មើសព្រះបញ្ជាម្ចាស់គេ ។"*



នេះគឺបុគ្គលដែលជឿស៊ប់ចិត្ត ពោលគឺ គេចងចាំជានិច្ចនូវព្រះឆន្ទៈអល់ឡោះហ្ម៍﷿ ។ គេមិនធ្វើអ្វីមួយដែលអល់ឡោះហ្ម៍﷿ហាមទេ គេធ្វើជានិច្ចនូវអ្វីដែលអល់ឡោះហ្ម៍﷿ចង់ឲ្យយើងធ្វើ ។ យើងទាំងអស់គ្នាគប្បីព្យាយាមប្រព្រឹត្តខ្លួនជាមុតតាគី ។

អល់ឡោះហ្ម៍﷿មានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ២ អាយ៉ាស់ ១៨៣) ថា ៖

*"បណ្តាអ្នកមានសទ្ធាអឺយ គេបានដាក់បញ្ញត្តិលើពួកអ្នកឲ្យកាន់សីលអត់អាហារ ដូចដែលធ្លាប់បានដាក់បញ្ញត្តិលើបណ្តាអ្នកសម័យមុនពួកអ្នករួចមកហើយដែរ ដើម្បីពួកអ្នកនឹងមានសទ្ធាធិមុត្ត[ចំពោះអល់ឡោះហ្ម៍] ។"*

**មេរៀនទី ៣**

# អធិប្បាយ ៣

## **កាហ្វៀរ** (كافر)

កាហ្វៀរគឺបុគ្គលដែលមិនជឿអល់ឡោះហ្វ៍ﷻ មិនជឿបណ្ដាព្រះសាស្ដាعليهم السلام មិនជឿបណ្ដាអ៊ីមុាំعليهم السلام ឬថ្ងៃជំនុំជម្រះទេ ។ បុគ្គលនេះមិនមែនមុស្លីមទេ ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ២ អាយ៉ាស់ ១៦១) ថា ៖
*"បណ្ដាពួកបដិសេធសទ្ធា ដែលស្លាប់នៅក្នុងភាពឥតសទ្ធា ពួកគេនឹងត្រូវបណ្ដាសាអល់ឡោះហ្វ៍ផង បណ្ដាទេវតាផង និងបណ្ដាមនុស្សផង ។"*

## **មុស្ហ្ររិក្ខ** (مشرك)

អ្នកមុស្ហ្ររិកជឿថាអល់ឡោះហ្វ៍ﷻមានសហការី (ដៃគូ) ពោល



គឺអ្នកនោះមិនជឿព្រះតែមួយទេ ។ នេះគឺបាបធំមួយដែលអល់ឡោះហ្វ៍ﷻមិនលើកលែងឲ្យទេ ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ៦ អាយ៉ាស់ ១០៦) ថា ៖
*"ចូរអ្នកប្រតិបត្តិតាមអ្វីដែលបានបើកឲ្យអ្នកដឹង [ដែលមក] ពីម្ចាស់របស់អ្នក ។ ពុំមានព្រះផ្សេងពីព្រះអង្គឡើយ ។ ចូរអ្នកគេចចេញពីបណ្ដាអ្នកដែលយកអ្វីផ្សេង (ពួករូបបដិមា...) មកចូលរួមហ៊ុនហាយជាមួយអល់ឡោះហ្វ៍ ។"*

## **មូណាហ្វិក្ខ** (منافق)

អ្នកមូណាហ្វិក្ខគឺអ្នកដែលថាខ្លួនជាមុស្លីម តែនៅក្នុងចិត្តអ្នកនោះមិនប្រតិបត្តិតាមសាសនាអ៊ីស្លាមទេ ។ អ្នកនេះជាអ្នកលាក់ពុត ។ មនុស្សប្រភេទនេះជាមនុស្សភូតភរ បោកប្រាស់ ធ្វើឲ្យអល់ឡោះហ្វ៍ទ្រង់ព្រះពិរោធបំផុត ។
អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ ៤ អាយ៉ាស់ ១៣៨) ថា ៖
*"ចូរអ្នកប្រកាសចំពោះបណ្ដាពួកមានពុតត្បុតថា ពួកគេនឹងទទួលទណ្ឌកម្មដ៏ឈឺចាប់ ។"*

## លំហាត់

ដូចដើមឈើដែលត្រូវការឫសមាំ មុស្លីមល្អក៏ត្រូវតែយល់យ៉ាងជ្រាលជ្រៅនិងជឿ ជាក់លើឫសកែវរបស់សាសនាជាចាំបាច់ដែរ ។

លើរូបភាពខាងក្រោមនេះ ចូរបំពេញន័យរបស់ពាក្យអារ៉ាប់ទាំងឡាយរបស់អ៊ូស្វ៊ូល អ៊ុដ្ឌីន ។






## មេរៀនទី ៤

# អ៊ូស្វ៊ូល អ៊ុដ្ឌីន

អ៊ូស្វ៊ូល អ៊ុដ្ឌីន គឺឫសកែវរបស់សាសនាយើង ។ គេហៅឫសកែវនោះផ្សេងទៀតថា អាក៏អ៊ីដ្ឋ (عقائد) ពោលគឺ គ្រឹះសាសនាយើង ។ ឫសកែវនោះមានប្រាំគឺ ៖

### ១. តៅហ៊ីដ្ឋ (មានអល់ឡោះហ្វ៍មួយគត់)

តៅហ៊ីដ្ឋមានន័យថា អល់ឡោះហ្វ៍គឺព្រះតែមួយគត់ ។ ព្រះអង្គមិនមានដៃគូ ឬ សហការីទេ ។ ព្រះអង្គមិនមានឪពុកម្តាយ មិនមានកូនទេ ។ ព្រះអង្គមិនត្រូវការអ្វី និងមិនត្រូវការអ្នកណាឡើយ តែទាំងអស់ត្រូវការព្រះអង្គ ។ ពុំមានអ្វីដូចព្រះអង្គឡើយ ។

### ២. អាដាឡាត់ (យុត្តិធម៌អល់ឡោះហ្វ៍)

អាដាឡាត់ មានន័យថា អល់ឡោះហ្វ៍ទ្រង់យុត្តិធម៌ ។ ព្រះអង្គមិនសាហាវឃោរឃៅទេ ។ ព្រះអង្គតបស្នងទាំងអស់គ្នាតាមទង្វើរបស់ម្នាក់ៗ ។ អ្នកណាគោរពតាមព្រះបញ្ជា

ទាំងឡាយរបស់ព្រះអង្គ អ្នកនោះនឹងត្រូវតបស្នងដោយបានទទួលនូវទីសំណាក់នៅឋានសួគ៌ ។ អ្នកណាប្រឆាំងព្រះអង្គ អ្នកនោះនឹងត្រូវបោះទៅក្នុងឋាននរក ។

## ៣. នូប៊ូវ៉ាត់ (តំណែងសាស្តា)

នូប៊ូវ៉ាត់មានន័យថាតំណែងសាស្តា ។ គឺជំនឿលើបណ្តាសាស្តាដែលអល់ឡោះហ្វ៍បានចាត់បញ្ជូនតរៀងមក ដើម្បីដឹកនាំមនុស្ស ។ អល់ឡោះហ្វ៍បានចាត់បញ្ជូនមក ១២៤០០០ សាស្តា ។ ព្រះសាស្តាអាដាំ عليه السلام ជាព្រះសាស្តាដំបូងបង្អស់ ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ជាព្រះសាស្តាចុងក្រោយបង្អស់ដែលអល់ឡោះហ្វ៍ عز وجل បានចាត់បញ្ជូនមក ។

## ៤. អ៊ីម៉ាម៉ាត់ (អ្នកស្នងព្រះសាស្តា)

បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានចូលទិវង្គតទៅ ភារកិច្ចដឹកនាំបណ្តាមុស្លីម ធ្លាក់មកលើបណ្តាអ៊ីមុាំ عليهم السلام ។ អល់ឡោះហ្វ៍បានជ្រើសរើស ១២ អ៊ីមុាំ عليهم السلام ។ អ៊ីមុាំអ៊ុាលី صلوات الله عليه والسلام ជាអ៊ីមុាំទីមួយ អ៊ីមុាំម៉ាស់ឌី صلوات الله عليه والسلام ជាអ៊ីមុាំចុងក្រោយ ។

ព្រោះតែអល់ឡោះហ្វ៍ عز وجل មានព្រះបំណង បានជាអ៊ីមុាំម៉ាស្ឌី صلوات الله عليه والسلام មានព្រះជន្មាយុនៅឡើយសព្វថ្ងៃនេះ ។ ព្រះអង្គ صلوات الله عليه والسلام



ជាអ៊ីមុាំរបស់សម័យកាលយើង ។

## ៥. គ្ញីយ៉ាម៉ាត់ (ថ្ងៃជំនំជម្រះ)

គ្ញីយ៉ាម៉ាត់ មានន័យថា ថ្ងៃជំនុំជម្រះ ឬ ថ្ងៃរស់ពីស្លាប់វិញ ។ គឺថ្ងៃដែលយើងរាល់គ្នា នឹងរស់ឡើងវិញដើម្បីជម្រះក្តីអំពីទង្វើទាំងឡាយដែលយើងបានធ្វើ ។ បន្ទាប់មក យោលតាមលទ្ធផលនៃទង្វើទាំងឡាយរបស់ខ្លួន ម្នាក់ៗនឹងត្រូវតបស្នងដោយបានចូលឋានសួគ៌ ឬដោយត្រូវបញ្ជូនទៅធ្វើទណ្ឌកម្មនៅឋាននរក ។

ហាក់ដូចជា បានទទួលនូវសេចក្ដីលំអៀងពីអល់ឡោះហ្ញ៉ា ។ ផ្ទុយទៅវិញ គ្រូពេទ្យបានទទួលនូវសមធម៌អល់ឡោះហ្ញ៉ា ។

ដូច្នេះ តើអល់ឡោះហ្ញ៉ាត្រឹមត្រូវលើពួកគេរាល់គ្នាទេ ? យើងឃើញថាការមិនលំអៀងនិងការគ្មានសមធម៌ មិនអធិប្បាយពណ៌នាអត្ថន័យរបស់អ៊ាដ្វាឡាត់ យ៉ាងពេញលេញបានទេ ។ ដើម្បីឲ្យយល់ យើងត្រូវដឹងថាអល់ឡោះហ្ញ៉ារក្សាឲ្យមាននូវលំនឹង ក្នុងសេចក្ដីត្រូវការរបស់សត្វលោកទាំងអស់របស់ព្រះអង្គ ។

យើងបែរមកមើលរឿងតំណាលនេះ តាមទស្សនៈមួយទៀត ។

គ្រូពេទ្យត្រូវអល់ឡោះហ្ញ៉ាប្រោសប្រណី ព្រោះគាត់មានអតិថិជនម្នាក់ថែមទៀត ។

បុរសចោរក៏ត្រូវអល់ឡោះហ្ញ៉ាទ្រង់ប្រោសប្រណីដែរ ព្រោះតែគាត់ឈឺបានជាគាត់មិនបានលួចគេ ។

ឯបុរសអ្នកធ្វើនំប៉័ង ក៏បានអល់ឡោះហ្ញ៉ាទ្រង់ប្រោសប្រណីដូចគេដែរ ព្រោះថា ថ្វីបើ គាត់មិនមានប្រាក់ចំណូលច្រើន



**មេរៀនទី ៥**

# សន្ទនាខ្លីៗអំពី អ៊ូស៊្ហូល អ៊ុដ្ឌីន ១

## ១. តៅហ៊ីដ (មានអល់ឡោះហ្ញ៉ាតែមួយគត់)

ថ្ងៃមួយ ព្រះសាស្ដាصلى الله عليه وآله وسلمនិងសាវ័កពីរបីនាក់របស់ព្រះអង្គصلى الله عليه وآله وسلم បានដើរមើល ហើយបានឃើញជីដូនម្នាក់ប្រកបកិច្ចការដោយត្បាល់កិន ដោយបួងសួងសូមឲ្យអល់ឡោះហ្ញ៉ាប្រោសប្រណី ។ ព្រះសាស្ដាصلى الله عليه وآله وسلمបានចូលទៅសួរសុខទុក្ខគាត់ ។ ព្រះអង្គصلى الله عليه وآله وسلمបានសួរគាត់ថា៖ "ការជឿជាក់របស់លោកយាយលើអល់ឡោះហ្ញ៉ាﷻគួរឲ្យសរសើរណាស់ ។ លោកយាយប្រាប់ខ្ញុំصلى الله عليه وآله وسلمបានទេថា អ្វីទៅដែលធ្វើឲ្យលោកយាយជឿជាក់លើអល់ឡោះហ្ញ៉ាﷻ ?"

បានឮដូច្នេះហើយ ជីដូនបានឈប់កិនមួយសន្ទុះ គាត់បានជញ្ជឹងគិតមួយភ្លែត ហើយបានថា៖ "រ៉ស៊្ហូលុលឡោះហ្ញ៉ាصلى الله عليه وآله وسلم អឺយ ! ព្រះអង្គصلى الله عليه وآله وسلمឃើញត្បាល់កិននេះទេ វាមិនអាចកម្រើកបានទេដរាបណាខ្ញុំម្ចាស់មិនបង្វិលវា ។ ត្បាល់កិនតូចមួយ

នេះអាចវិលបាន ចុះហេតុអ្វីភពផែនដែនចក្រវាលដែលមហាធំធេងអាចដំណើរការទៅបានយ៉ាងល្អប្រសើរ ដោយគ្មានកម្លាំងនីមួយអូសវានោះ ? ត្រូវតែមានអ្នកណាម្នាក់ធ្វើឲ្យវាដំណើរការទៅបានជាចាំបាច់ ។ អ្នកដែលបញ្ជាសព្វបែបយ៉ាងបានមិនមែនអ្នកណាក្រៅពីអល់ឡោះហ្វ៍ﷻទេ ព្រះអ្នកបង្កើត ព្រះម្ចាស់សព្វសារពើ ។

រ៉សូលុលឡោះហ្វ៍ﷺមានសេចក្តីសោមនស្សអនេក អំពីចម្លើយរបស់ជីដូនរូបនេះ ។ ព្រះអង្គﷺបានប្រាប់បណ្តាសាវ័កព្រះអង្គﷺថា៖ "អស់លោកឃើញជីដូនរូបនេះទេ គាត់យល់អល់ឡោះហ្វ៍ﷻយ៉ាងងាយស្រួលបំផុត ។ ជំនឿរបស់អស់លោកលើអល់ឡោះហ្វ៍ﷻ គួរតែមាំមួនដូចជំនឿគាត់ដែរ ។"

## ២. អាុដ្វាឡាត់ (យុត្តិធម៌អល់ឡោះហ្វ៍)

យុត្តិធមិអល់ឡោះហ្វ៍មិនមានន័យថា អល់ឡោះហ្វ៍ស្មើភាពចំពោះទាំងអស់គ្នានោះទេ ។ ស្មើភាពនិងត្រឹមត្រូវមិនដូចគ្នាទេ ។



ពេលគេប្រើពាក្យយុត្តិធមិសម្រាប់អល់ឡោះហ្វ៍ មានន័យថា ព្រះអង្គរក្សាឲ្យមានលំនឹង រវាងសេចក្តីត្រូវការរបស់ជីវន្តលោកទាំងអស់របស់ព្រះអង្គ ។

រឿងតំណាលតទៅនេះនឹងឲ្យអ្នកយល់បានថា អល់ឡោះហ្វ៍ទ្រង់ព្រះអាុឌិល (គឺយុត្តិធមិ) ដូចម្តេចខ្លះ ។

គ្រូពេទ្យម្នាក់ អ្នកធ្វើនំប៉័ងម្នាក់និងចោរម្នាក់ រស់នៅក្នុងស្រុកមួយ ។ រៀងរាល់ព្រឹក ទាំងបីនាក់នេះបួងសួងអល់ឡោះហ្វ៍ សូមឲ្យព្រះអង្គបង្កើនព្រះឧបការគុណមកលើពួកគេ ។

ថ្ងៃនេះ បុរសចោរមានគម្រោងការលួចបុរសអ្នកធ្វើនំប៉័ង តែគាត់ធ្លាក់ខ្លួនឈឺ ហើយចាំបាច់ទៅជួបគ្រូពេទ្យ ។ រីឯបុរសអ្នកធ្វើនំប៉័ងនោះវិញ គាត់មិនរកបានប្រាក់ច្រើនទេ ព្រោះមានភ្លៀងធ្លាក់ បណ្តាលឲ្យអតិថិជនរបស់គាត់ចេញពីផ្ទះមិនរួច ។

យើងបែរមកសិក្សារឿងតំណាលនេះ ។

បុរសចោរ ព្រោះតែឈឺ ឯបុរសអ្នកធ្វើនំប៉័ង ព្រោះតែភ្លៀង

## ៤. អ៊ីម៉ាម៉ាត់ (ឧត្តរាធិការីព្រះសាស្តា)

ថ្ងៃមួយ បុរសម្នាក់បានសាងសង់ម៉ាស៊ីនឆ្លាតមួយ ។ គេឃើញថាវាមានប្រយោជន៍ ហើយបានទិញវាយកទៅប្រើប្រាស់ជាធម្មតា ។ មុនស្លាប់ បុរសនេះបានបង្ហាត់បង្រៀនសិស្សគាត់ឲ្យចេះជួសជុលម៉ាស៊ីន ពេលវាខូចឬដំណើរការមិនប្រក្រតី ។ ក្រោយពីគាត់បានស្លាប់ទៅ រាល់គ្រាដែលគេមានបញ្ហាជាមួយម៉ាស៊ីន គេមករកសិស្សរបស់គាត់ដើម្បីដោះស្រាយបញ្ហា ។

ដូចគ្នាដែរ ទោះបីព្រះសាស្តាﷺបាននាំមកនូវច្បាប់ទាំងអស់ក៏ដោយ ក្រោយពីព្រះអង្គﷺសោយទិវង្គតទៅ ក៏គេត្រូវការអ្នកណាម្នាក់ ដែលមានសមត្ថភាពឆ្លើយតបសំណួរមនុស្សដែរ ។ អ៊ីម៉ាំعليهم السلامដែលត្រូវអល់ឡោះហ្វ៍عز وجلជ្រើសរើសជាអ្នកបន្តវេនដើម្បីពន្យល់ភារកិច្ចរបស់ព្រះសាស្តាﷺ ។

## ៥. គ្វីយ៉ាម៉ាត់ (ថ្ងៃជំនុំជម្រះ)

មានបុរសមុស្លីមម្នាក់បានចាប់ផ្តើមផឹកសុរា ។ គាត់បានលួច



ក៏ដោយ តែគាត់បានរួចផុតពីការលួចប្លន់ ។

យើងបានឃើញហើយថា អ៊ុដ្វាឡាត់ មានន័យថាអល់ឡោះហ្វ៍ក្តាប់ទុកនូវលំនឹង រវាងសេចក្តីត្រូវការរបស់សត្វលោកទាំងអស់របស់ព្រះអង្គ ។

## លំហាត់

ចូរអ្នកអានសម្រាយរបស់ស៊ូរ៉ោះត៍ អាត់-តៅហ្វ៊ីដ្ វ (ស៊ូរ៉ោះត៍ ១១២) ហើយចូរឆ្លើយ សំណួរខាងក្រោមនេះ ។

១. តើអាយ៉ាស់ទីមួយស្ដីអំពីអ្វីខ្លះទាក់ទងនឹងអល់ឡោះហ្វ៍ ?

២. តើអាយ៉ាស់ទីពីរស្ដីអំពីអ្វីខ្លះទាក់ទងនឹងសេចក្ដីត្រូវការ ?

៣. តើអាយ៉ាស់ទីបីស្ដីអំពីអ្វីខ្លះ ទាក់ទងនឹងបុត្រព្រះអង្គ មាតាបិតាព្រះអង្គ ?

៤. តើអាយ៉ាស់ចុងក្រោយស្ដីអំពីអ្វីខ្លះ ទាក់ទងនឹង អល់ឡោះហ្វ៍ ?



## មេរៀនទី ៦

# សន្ធនាខ្លីៗអំពី អ៊ូស្ហ៊ូល អ៊ុដ្ឌីន ២

### ៣. នូប៊ូវ៉ាត់ (តំណែងសាស្ដា)

បុរសពីរនាក់ធ្វើដំណើរជាមួយគ្នា ហើយបានរាប់រកគ្នាជាមិត្ត ។ លុះបានដល់គោលដៅ ម្នាក់បានអញ្ជើញមិត្តខ្លួនទៅទទួលទានអាហារថ្ងៃស្អែក ។ តែគាត់មិនបានឲ្យអាសយដ្ឋាននិងលេខទូរស័ព្ទទៅមិត្តគាត់ទេ ។ មិត្តគាត់ចង់ទៅទទួលទានអាហារឯផ្ទះគាត់ តែទៅបានដូចម្ដេច ? គាត់មិនដឹងនឹងធ្វើដូចម្ដេចទេ ។

អល់ឡោះហ្វ៍عز وجلបានបង្កើតយើងមក ដើម្បីនឹងឲ្យយើងគោរពបូជាព្រះអង្គ ។ ប្រសិនបើព្រះអង្គعز وجلមិនបានចាត់បញ្ជូនព្រះសាស្ដាعليهم السلامជាមអ្នកទេសក៏មករកយើងទេ តើយើងអាចគោរពបូជាព្រះអង្គعز وجلបានដូចម្ដេចទៅ ? ដើម្បីឲ្យយើងរកព្រះអង្គعز وجلឃើញ បានជាព្រះអង្គعز وجلចាត់បញ្ជូនច្រើនព្រះសាស្ដាعليهم السلام មកដើម្បីបង្ហាញផ្លូវយើង ។

**២. ស្ងៅម៍ (ត្រណមអាហារក្នុងខែរ៉ម៉ាដូន)**

អល់ឡោះហ្ជ៏ាមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"បណ្តាអ្នកមានសទ្ធាអឺយ គេបានដាក់បញ្ញត្តិលើពួកអ្នកឲ្យកាន់សីលអត់អាហារ ដូចដែលធ្លាប់បានដាក់បញ្ញត្តិលើបណ្តាអ្នកសម័យមុនពួកអ្នករួចមកហើយដែរ ដើម្បីពួកអ្នកនឹងមានសទ្ធាធិមុត្ត[ចំពោះអល់ឡោះហ្វ] ។" (២:១៨៣)*

ការកាន់សីលតមអាហារក្នុងខែរ៉ម៉ាដូន ជាកាតព្វកិច្ចលើមុស្លីមគ្រប់រូបរៀងរាល់ឆ្នាំ ។ ចាប់ផ្តើមពីមុនថ្ងៃរះ (ស្វុបហ៊្ សូ្ឌិក្វ) ចប់ពេលម៉ាក់រីប (ថ្ងៃលិច) ។

**៣. ហ្វាជ្ជ៍ (ពិធីបូជនីយេសចរណ៍នៅឯម៉ាក់កាស្វ)**

អល់ឡោះហ្ជ៏ាមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"ចូរពួកអ្នកបំពេញពិធីបូជនីយេសចរណ៍ (ហ្វាជ្ជ) និងអ៊ុមរ៉ោះត៍ដើម្បីអល់ឡោះហ្វ ។" (២:១៩៦)*

មុស្លីមគ្រប់រូបត្រូវតែទៅបំពេញពិធីហ្វាជ្ជ៍ មួយដងក្នុង



ផឹកនៅឯផ្ទះគាត់ ។ ថ្ងៃមួយ កុមារម្នាក់បានចូលក្នុងបន្ទប់គាត់ បានឃើញគាត់ ។ ពេលនេះគាត់ខ្លាចបំផុត តើក្មេងនេះនឹងប្រាប់គេឲ្យដឹងអំពីអ្វីដែលវាបានឃើញទេ ? បុរសរូបនេះនឹងធ្វើយ៉ាង ណាចំពោះមុខគ្រួសារគាត់និងមិត្តគាត់នៅឯម៉ាស់ឃ្ជិដ្ ? គាត់ដេកមិនលក់ដោយសារតែគាត់បារម្ភអំពីអ្នកផងនិយាយរឿងគាត់ផឹក ។

បុរសរូបនេះប្លែកមែន ! គាត់ខ្លាចកុមារនោះជាងខ្លាចអល់ឡោះហ្ជ៏ាទៅទៀត ។ អល់ឡោះហ្ជ៏ាមើលឃើញអ្វីសព្វគ្រប់ដែលយើងធ្វើ នឹងមានថ្ងៃមួយដែលយើងនឹងត្រូវធ្វើសេចក្តីរាយការណ៍អំពីទង្វើទាំងអស់របស់យើង ។ ថ្ងៃនោះគឺថ្ងៃជំនុំជម្រះ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ហេតុអ្វីអល់ឡោះហ្ហ៍عز وجلបានចាត់បញ្ជូន ព្រះសាស្តាعليهم السلام មក ?
២. ហេតុអ្វីយើងត្រូវការអ៊ីម៉ាំعليهم السلام ?
៣. ហេតុអ្វីអល់ឡោះហ្ហ៍عز وجلបានត្រៀមថ្ងៃជំនុំជម្រះ ?



## មេរៀនទី ៧

# ហ្វ៊ូរ៉អ៊ុដ្ឌីន ១

ហ្វ៊ូរ៉អ៊ុដ្ឌីនជាសាខារបស់សាសនា ។ ជាកិច្ចប្រតិបត្តិក្នុងការធ្វើសក្ការបូជាអល់ឡោះហ្ហ៍عز وجلដែលយើងត្រូវធ្វើ ពេលយើងបានយល់អ៊ូស្វ៊ូល អ៊ុដ្ឌីន ។

ហ្វ៊ូរ៉អ៊ុដ្ឌីនមាន ១០ ប្រការ គឺ ៖

**១. ស្វ៉ឡាត់ (នមស្ការប្រចាំថ្ងៃ)**

អល់ឡោះហ្ហ៍عز وجلមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖
*"ចូរពួកអ្នកស្វែងរកជំនួយក្នុងអំណត់ និងក្នុងនមស្ការ[បូជាអល់ឡោះហ្ហ៍] ។" (២:៤៥)*

មាន ១៧ រ៉ក់អ៊ាត់ក្នុងនមស្ការប្រចាំថ្ងៃគឺ ៖
ហ្វាច់រ៍ ២ រ៉ក់អ៊ាត់, ស្ហ៊ុស្ហ៍ ៤ រ៉ក់អ៊ាត់, អ៊ាស្វ៉ រ៍ ៤ រ៉ក់អ៊ាត់, ម៉ាក់រីប ៣ រ៉ក់អ៊ាត់, អ៊ីស្ហាអ៍ ៤ រ៉ក់អ៊ាត់ ។

**មេរៀនទី ៨**

# ហ្វ៊ូរូអ៊ុដ្ឌីន ២

**៦. យ៊ីហ្វាដ្ (اَلْجِهَادُ ប្រយុទ្ធដើម្បីអល់ឡោះហ៍)**

អល់ឡោះហ៍﷿មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"សាស្តាអើយ ចូរអ្នកលើកទឹកចិត្តអ្នកមានសទ្ធាទាំងឡាយឲ្យមានសេចក្តីក្លាហានដើម្បីប្រយុទ្ធ ។ បើមានចំនួនម្ភៃនាក់ក្នុងចំណោមពួកអ្នកដែលអត់ធ្មត់ ពួកគេនឹងដណ្តើមយកបាននូវជ័យជំនះលើសត្រូវដែលមានចំនួនពីររយនាក់ ។" (៨:៦៥)*

យ៊ីហ្វាដ្មានន័យថាប្រយុទ្ធដើម្បីអល់ឡោះហ៍﷿ តាមការកោះហៅរបស់ព្រះសាស្តាﷺ ឬ អ៊ីម៉ាំសម័យកាល ។ មិនមែនប្រយុទ្ធដោយអាវុធតែមួយមុខទេ អាចប្រយុទ្ធដោយសំណេរ ឬដោយសំដី ។

**៧. អាំរ៍ ប៊ិលម៉ាក់រ៊ូហ្វ (اَلْأَمْرُ بِالْمَعْرُوفِ ណែនាំគេឲ្យធ្វើល្អ)**



មួយជីវិតនៅឯម៉ាក់កាស្ទ ពេលមានលទ្ធភាព ។

**៤. ស្សាកាត់ (សទ្ធាទាន)**

អល់ឡោះហ៍﷿មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"បណ្តាអ្នកមានសទ្ធា[ចំពោះអល់ឡោះហ៍] ប្រព្រឹត្តអំពើល្អ បំពេញនមស្ការ[បូជាអល់ឡោះហ៍] យ៉ាងខ្ជាប់ខ្ជួននិងបរិច្ចាគសទ្ធាទាន ជនទាំងនោះនឹងមានរង្វាន់នៅឯម្ចាស់ពួកគេ ។" (២:២៧៧)*

ស្សាកាត់ជាវិភាគទាន ដែលគេត្រូវតែបរិច្ចាគលើរបស់មួយចំនួន ហើយដែលគេត្រូវឲ្យទៅមុស្លីមស្ទើអាស្ទក្រីក្រ ។

**៥. ឃុមស៍ (ពន្ធអ៊ីស្លាមមួយភាគប្រាំ)**

អល់ឡោះហ៍﷿មានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"ចូរអ្នកទាំងឡាយដឹងថា អ្វីៗទាំងអស់ដែលពួកអ្នកបានប្រមូលយកជាទ្រព្យឈ្លើយ មួយភាគប្រាំនៃអ្វីទាំងនោះជាកម្មសិទ្ធិរបស់អល់ឡោះហ៍របស់សាស្តា ។" (៨:៤១) ។*

ម្នាក់ៗត្រូវបរិច្ចាគមួយភាគប្រាំនៃប្រាក់ចំណេញ (ផាត់ទាត់រួច) ក្នុងមួយឆ្នាំ ។ ចំនួនទឹកប្រាក់ត្រូវបែងចែកឲ្យទៅរាជវង្សរបស់រ៉សូលុលឡោះហ៍ﷺនិងអ៊ីម៉ាំទី ១២ របស់យើង ។ ក្នុងសម័យ កុំយ់បាស់ គេឲ្យទៅមុច្ចតាហ៊្វីដ (مُجْتَهِد) ។



## លំហាត់

ចូររៀវរកអាយ៉ាស់ដទៃទៀតនៅក្នុងគួរអាន ដែលស្តីអំពីស៊ូឡាត់ ។ មើលក្នុងស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ូន ហើយសរសេរសម្រាយស៊ូរ៉ោះត៍នេះ ។

## មេរៀនទី ៩

# វូឌុអ៊ុ (وُضُوء)

វូឌុអ៊ុជាវិធីលាងសម្អាតពិសេស ដែលធ្វើឲ្យយើងស្អាតទៅតាមសាសនា ។ វិធីវូឌុអ៊ុ មានការលាងមុខ លាងដៃទាំងពីរ និងការជូតក្បាលប៉ែកខាងមុខ និងជើងទាំងពីរប៉ែកខាងលើ ។

ចាំបាច់ត្រូវមានទឹកវូឌុអ៊ុសម្រាប់ ៖

១. បំពេញស្វ៉ឡាត់
២. បំពេញត៏វ៉ាហ្វ
៣. ប៉ះអក្សរសំណេរក្នុងព្រះមហាគម្ពីរគួរអាន ។
៤. ប៉ះព្រះនាមអល់ឡោះហ្វ៍ﷻ និងបុគ្គលបរិសុទ្ធ (គឺម៉ាក់ស្វូមីន) ទាំង ១៤ រូបعليهم السلام ។

**លក្ខខណ្ឌវូឌុអ៊ុ**



**៨. ណាស់យ៉ា អ៊ុនីល-មុនការ** (اَلنَّهْيَ عَنِ الْمُنْكَرِ **ហាមគេមិនឲ្យធ្វើអាក្រក់**)

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលក្នុងព្រះគម្ពីរគួរអានថា៖ *"ចូរឲ្យមាននៅក្នុងចំណោមពួកអ្នក នូវសហគមន៍មួយដែលហៅទៅរកសេចក្ដីល្អប្រពៃ បង្គាប់ឲ្យប្រព្រឹត្តល្អ[តាមព្រះគម្ពីរអល់ឡោះហ្វ៍និងតាមព្រះសាស្ដាព្រះអង្គ] ហាមប្រព្រឹត្តអាក្រក់ (គឺហាមអ្វីដែលអល់ឡោះហ្វ៍ហាម) ។ ជនទាំងនោះជាជនដែលនឹងបាននូវជ័យជំនះ [បានដល់សុខុមាលភាពនៃឋានសួគ៌] ។" (៣:១០៤)*

ប្រសិនបើយើងឃើញអ្នកណាមួយធ្វើអំពើល្អ យើងគប្បីអបអរសាទរលើកទឹកចិត្តអ្នកនោះឲ្យធ្វើអំពើល្អ ។ នេះគេហៅថា អាំរ៍ ប៊ិលម៉ាក់រូហ្វ ។

ប្រសិនបើយើងឃើញអ្នកណាមួយធ្វើអំពើអាក្រក់ យើងគប្បីព្យាយាមហាមឃាត់អ្នកនោះ មិនឲ្យធ្វើអំពើអាក្រក់នោះ ។ នេះគេហៅថា ណាស់យ៉ា អ៊ុនីល-មុនការ ។

**៩. តាវ៉ាល់ឡា (تَوَلَّى ស្រឡាញ់មិត្តរបស់ម៉ាក់ស៊្ហូមីនعليهم السلام)**

**១០. តាបារ៉ា (تَبَرَّأ ស្អប់សត្រូវរបស់ម៉ាក់ស៊្ហូមីនعليهم السلام)**

ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "អ្នកណាធ្វើឲ្យបុត្រីسلام الله عليهاខ្ញុំصلى الله عليه وآله وسلمពេញចិត្ត អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمពេញចិត្ត អ្នកណាធ្វើឲ្យបុត្រីسلام الله عليهاខ្ញុំصلى الله عليه وآله وسلمឃ្នើសចិត្ត អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمឃ្នើសចិត្ត ។"

តាវ៉ាល់ឡាមានន័យថា ប្រតិបត្តិតាមសិក្ខាបទរបស់ម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គ និងរក្សាមិត្តភាពជាមួយបក្សពួករបស់ម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គនោះ ។

តាបារ៉ាមានន័យថាដកខ្លួនចេញពីអ្នកណាដែលស្អប់ ឬ មិនប្រតិបត្តិតាមម៉ាក់ស៊្ហូមីនعليهم السلامទាំង ១៤ អង្គ ។



## លំហាត់

អល់ឡោះហ្វ៍عز وجلប្រាប់យើងថា ហេតុអ្វីយើងត្រូវស្រឡាញ់ម៉ាក់ស៊្ហូមីននៅចុងស៊ូរ៉ោះត៍ ៣៣ (អាល់-អាស៊្ហស្ហាប់) អាយ៉ាស់ ៣៣ ។

ហើយព្រះអង្គព្រមានយើងដែរ ឲ្យយើងប្រយ័តខ្លួនកុំប្រឆាំងព្រះសាស្ដាصلى الله عليه وآله وسلمនៅក្នុង ស៊ូរ៉ោះត៍ដដែល អាយ៉ាស់ ៥៧ ។

ចូរមើលសម្រាយអាយ៉ាស់ទាំងពីរនេះ ហើយសរសេរវានៅខាងក្រោមនេះ ។

៣. ដេកលក់

៤. បាត់បង់ស្មារតី ។



១. គ្រប់ប៉ែករបស់អវយវៈ ដែលប៉ះទឹកវូឌូអ៍ចាំបាច់ត្រូវស្អាត (គ្មានអ្វីបិទបាំងជាដើម) ។

២. ត្រូវប្រើទឹកត្ហ៊ូហៀរ (គឺបរិសុទ្ធ) ទឹកមូបាហ៍ (អនុញ្ញាត) និងទឹកមុតឡាក់ (គឺទឹកបរិសុទ្ធ មិនលាយអ្វីផ្សេង) ។

៣. កន្លែងយកទឹកវូឌូអ៍ត្រូវមូបាហ៍ (អនុញ្ញាត) ។

៤. គោលបំណង (នៀត) គឺត្រូវតែ គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍ (ដើម្បីទៅរកអល់ឡោះហ្វ៍ﷻ) ។

៥. តារទិប (ترتيب) ៖ ការយកទឹកវូឌូអ៍ត្រូវប្រព្រឹត្តទៅតាមលំដាប់ ។

៦. មូវ៉ាឡាត់ (مُوَالَاة) ៖ ការយកទឹកវូឌូអ៍ត្រូវប្រព្រឹត្តទៅមិនដាច់ (មិនឈប់យូរពេក) ។

៧. ការយកទឹកវូឌូអ៍ត្រូវប្រព្រឹត្តទៅដោយខ្លួនឯង មិនមានគេជួយ លើកលែងតែពិការ ឬ មានជម្ងឺ ។

៨. ក្នុងពេលយកទឹកវូឌូអ៍ ត្រូវយកថ្នាំលាបក្រចកចេញ

ដោះចិញ្ចៀន និងនាឡិកា ។ ទឹកត្រូវជ្រាបទៅដល់ប៉ែកអវយវៈទាំងនេះ ។

**ទង្វើស៊ូណាត់ក្នុងវូឌុអ៊ុ**

១. លាងមុខនិងដៃទាំងពីរ ពីរដង ។

២. ខ្ពុរមាត់ ៣ ដង ។

៣. ជម្រះរន្ធច្រមុះ ៣ ដង ។

ទង្វើស្ទូណាត់ទាំងអស់ក្នុងវូឌុអ៊ុត្រូវធ្វើមុនទង្វើវ៉ាយ៊ីប ។

**ទង្វើវ៉ាយ៊ីបក្នុងវូឌុអ៊ុ**

១ នៀតះ "ខ្ញុំយកទឹកវូឌុអ៊ុដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្វ គួរបាត្ទន់ អ៊ិលឡុលឡោះហ្វ ។"

២ លាងមុខះ ចាប់ពីថ្ងាស (គឺពីជើងសក់) រហូតដល់ចង្កាទទឹងក្នុងចន្លោះមេដៃនិងម្រាមកណ្ដាល ។



៣ លាងដៃស្ដាំះ ចាប់ពីកែងដៃដល់ចុងម្រាបដៃ ។

៤ លាងដៃឆ្វេងះ ចាប់ពីកែងដៃដល់ចុងម្រាបដៃ ។

៥ ម៉ាសាស្ហ (គឺជូត) ក្បាលះ យកម្រាមដៃស្ដាំទទឹកជូតលើក្បាល ។ អូសម្រាមដៃ ចាប់ពីពាក់កណ្ដាលក្បាលមករកថ្ងាសដោយមិនឲ្យប៉ះទឹកលើថ្ងាស ។ ក្នុងពេលជូតនេះត្រូវឲ្យក្បាលនឹង ។

៦ ជូតជើងទាំងពីរះ យកម្រាមដៃស្ដាំទទឹកជូតប៉ែកខាងលើរបស់ប្រអប់ជើងស្ដាំ ។ អូសម្រាមដៃចាប់ពីចុងមេជើងរហូតមកដល់គន្លាក់ជើង (គឺកជើង) ។ រួចហើយ ជូតជើងឆ្វេងដោយវិធីដូចគ្នា ដោយប្រើដៃឆ្វេង ។

**អ្វីដែលធ្វើឲ្យខូចទឹកវូឌុអ៊ុ**

១. បន្ទោបង់ (គឺបត់ជើងតូច បត់ជើងធំ) ។

២. ដើរខ្យល់ (គឺដោម) ។

អល់ឡោះហ្វ៍មហាធំធ្កើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្ដេជ្ញាថា មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្ដេជ្ញាថា មូហាំម៉ាដ្ជជាព្រះសាស្ដារបស់អល់ឡោះហ្វ៍ ។

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដងហើយ)

ខ្ញុំសូមប្ដេជ្ញាថាអាលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ ។

حَيَّ عَلَى الصّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញនមស្ការ(បូជាអល់ឡោះហ្វ៍) ។

حَيَّ عَلَى الْفَلَاحِ (២ ដងហើយ)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។



## លំហាត់

ចូរហ្វឹកហាត់តាមសេចក្ដីណែនាំឲ្យស្ទាត់ ។

**មេរៀនទី ១០**

# អាសុាន និង អ៊ីកុ៏ម៉ាស៊ុ

**អាសុាន - ប្រកាសនមស្ការ**

اَللّٰهُ اَكْبَرُ (៤ ដង)

អល់ឡោះហ្វ៍មហាធំធ្ងើងបំផុត

اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថា មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថា មូហាំម៉ាដ៉ុជាព្រះសាស្តារបស់អល់ឡោះហ្វ៍ ។

اَشْهَدُ اَنَّ عَلِيًّ وَّلِيُّ اللّٰهُ (២ ដង)

ខ្ញុំសូមប្តេជ្ញាថាអាុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ ។



حَيَّ عَلَى الصَّلَاةِ (២ ដង)

ចូរអ្នកប្រញាប់មកបំពេញនមស្ការ(បូជាអល់ឡោះហ្វ៍) ។

حَيَّ عَلَى الْفَلَاحِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ ។

حَيَّ عَلَى خَيْرِ الْعَمَلِ (២ ដង)

ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

اَللّٰهُ اَكْبَرُ (២ ដង)

អល់ឡោះហ្វ៍មហាធំធ្ងើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (២ ដង)

មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

**អ៊ីកុ៏ម៉ាស៊ុ - សូត្រមុនចាប់ផ្តើមបំពេញនមស្កា(បូជាអល់ឡោះហ្វ៍)**

اَللّٰهُ اَكْبَرُ (២ ដងហើយ)

៥. ស៊ូណាត់ឲ្យសូត្រស្ទាត់ៗ តាមអ្នកសូត្រត្រង់កន្លែងដែលបានឮ ។

៦. ស៊ូណាត់ឲ្យអ្នកសូត្រមានទឹកវូឌុអ៍ និងឈរបែរមុខទៅរកគីបឡាស់ក្នុងអំឡុងពេលសូត្រអាសាន ។ គប្បីដាក់ដៃលើត្រចៀកនិងប្រើសម្លេងខ្លាំង ។ គប្បីឈប់បន្តិចក្នុងចន្លោះឃ្លានីមួយៗ និងមិននិយាយស្តីជាមួយគេក្នុងអំឡុងពេលសូត្រនេះ ។



حَيَّ عَلَى خَيْرِ الْعَمَلِ (២ ដងហើយ)
ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត ។

قَدْ قَامَتِ الصَّلَاةِ (២ ដង)
នមស្ការ(ស្វ៏ឡាត់)ចាប់ផ្តើមហើយ ។

اَللّٰهُ اَكْبَرُ (២ ដងហើយ)
អល់ឡោះហ្វ៍មហាធំធ្មើងបំផុត

لَا اِلٰهَ اِلَّا اللّٰهُ (១ ដងហើយ)
មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

**តារាងប្រៀបធៀបអាសាន និង អ៊ីក៏្វម៉ាស់**

| របៀបសូត្រ | អាសាន | អ៊ីក៏្វម៉ាស់ |
|---|---|---|
| اَللّٰهُ اَكْبَرُ<br>អល់ឡោះហ្វ៍មហាធំធ្មើងបំផុត | ៤ ដង | ២ ដង |
| اَشْهَدُ اَنْ لَّا اِلٰهَ اِلَّا اللّٰهُ<br>ខ្ញុំសូមប្តេជ្ញាថា មិនមានព្រះផ្សេងពី | ២ ដង | ២ ដង |

| | | |
|---|---|---|
| អល់ឡោះហ្វ៍ឡើយ | | |
| اَشْهَدُ اَنَّ مُحَمَّدًا رَّسُوْلُ اللّٰهُ<br>ខ្ញុំសូមប្ដេជ្ញាថាមូហាំម៉ាដ្ទជាព្រះសាស្ដារបស់អល់ឡោះហ្វ៍ | ២ ដង | ២ ដង |
| اَشْهَدُ اَنَّ عَلِيَّ وَّلِيُّ اللّٰهُ<br>ខ្ញុំសូមប្ដេជ្ញាថាអាុលីជាទីស្រឡាញ់របស់អល់ឡោះហ្វ៍ | ២ ដង | ២ ដង |
| حَيَّ عَلَى الصَّلاَةِ<br>ចូរអ្នកប្រញាប់មកបំពេញនមស្ការ (បូជាអល់ឡោះហ្វ៍) | ២ ដង | ២ ដង |
| حَيَّ عَلَى الْفَلاَحِ<br>ចូរអ្នកប្រញាប់ឆ្ពោះទៅរកជោគជ័យ | ២ ដង | ២ ដង |
| حَيَّ عَلَى خَيْرِ الْعَمَلِ<br>ចូរអ្នកប្រញាប់ឆ្ពោះទៅរកទង្វើដ៏ល្អបំផុត | ២ ដង | ២ ដង |
| قَدْ قَامَتِ الصَّلاَةِ<br>នមស្ការ(ស្វ៏ឡាត់)ចាប់ផ្ដើមហើយ | ០ ដង | ២ ដង |
| اَللّٰهُ اَكْبَرُ<br>អល់ឡោះហ្វ៍មហាធំថ្កើងបំផុត | ២ ដង | ២ ដង |
| لاَ اِلٰهَ اِلَّا اللّٰهُ<br>មិនមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ | ២ ដង | ១ ដង |



## លក្ខខណ្ឌរបស់អាសាុននិងអ៊ីក៏ម៉ាស់

១. សូត្រអាសាុននិងអ៊ីក៏ម៉ាស់ មុនបំពេញស្វ៏ឡាត់វ៉ាឃ៊ិបប្រចាំថ្ងៃ ជាស៊ូណាត់សម្រាប់គ្រប់គ្នា ។ ក៏ប៉ុន្ដែសម្រាប់ស្វ៏ឡាត់ដែលមិនមែនស្វ៏ឡាត់ប្រចាំថ្ងៃ ដូចជាស្វ៏ឡាត់អ៊ីដ្ទជាដើមដែលធ្វើរួមគ្នា (ឃ៊ុមអាុត់) ស៊ូណាត់ឲ្យសូត្រថា "អាស់-ស្វ៏ឡាត់" ៣ ដង មុនចាប់ផ្ដើមបំពេញស្វ៏ឡាត់ ។

២. ចាំបាច់ត្រូវសូត្រក្រោយពីពេល ស្វ៏ឡាត់ចូលមកដល់ មិនឲ្យសូត្រមុនទេ ។

៣. ចាំបាច់ត្រូវសូត្រជាភាសាអារ៉ាប់ត្រឹមត្រូវ (ម៉ាក់រ៉ច៊់) ។ មិនត្រូវសូត្រដូចគេច្រៀងទេ នឹងធ្វើឲ្យបាទិ្ទល (ខូច) ។

៤. មិនត្រូវឈប់ខុសធម្មតាទេ នៅចន្លោះឃ្លានីមួយៗ ។

## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ពេលណាស្ទ័ឡាត្ទ់ទៅជាវ៉ាយ៉ុបសម្រាប់មុស្លីម ?

២. ហេតុអ្វីបានជាស្ទ័ឡាត្ទ់សំខាន់សម្រាប់យើង ?

៣. ចូរប្រាប់ឈ្មោះស្ទ័ឡាត្ទ់ប្រចាំថ្ងៃ និងចំនួនរ៉ក់អាត្ទ់ ?

៤. អ្វីទៅស្ទ័ឡាត្ទ់អាយ៉ាស់ និង ស្ទ័ឡាត្ទ់ ម៉ាយិត ?

៥. តើមានស្ទ័ឡាត្ទ់វ៉ាយ៉ុបផ្សេងទៀតទេ ?



## លំហាត់ ១

សូមឪពុកម្ដាយអ្នកឲ្យលោកបង្ហាញអ្នក ។

## លំហាត់ ២

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. ពេលណាចាំបាច់ត្រូវមានវុឌុអ៊ ?

២. អ្វីទៅលក្ខខណ្ឌវុឌុអ៊ ទាក់ទងនឹងទឹក ?

៣. អ្វីទៅលក្ខខណ្ឌវុឌុអ៊ផ្សេងទៀត ?
 -ទង្វើវ៉ាយ៉ុប
 -ទង្វើស៊ូណាត្ទ់

៤. អ្វីខ្លះដែលធ្វើឲ្យវុឌុអ៊ខូច ?

## មេរៀនទី ១១

# ស៊្ឡាត់

ស៊្ឡាត់ជាវ៉ាយ៊ីបសម្រាប់មុស្លីមប្រាំដងក្នុងមួយថ្ងៃ ។

ស៊្ឡាត់ជាវ៉ាយ៊ីបសម្រាប់មុស្លីមបាលិក៊ុ (ពេញវ័យ) ។ ប្រុសៗពេញវ័យ (បាលិក៊ុ) ពេលដល់អាយុ ១៥ ឆ្នាំយ៉ាងច្រើន ឯស្រីៗគ្រប់វ័យពេលបានដល់អាយុ ៩ ឆ្នាំ ។

ស៊្ឡាត់ជាមូលដ្ឋានសំខាន់ បំផុតរបស់សាសនាអ៊ីស្លាម ។ ជាចំណុចចម្បង និងជាកាតព្វកិច្ចសំខាន់បំផុតរបស់មុស្លីម ។ នៅក្នុងព្រះមហាគម្ពីរគួរអាន អល់ឡោះហ្វ៍عزوجلបានថែងលើសពី ៨០ ដង ។ អល់ឡោះហ្វ៍عزوجلចាត់ទុកស៊្ឡាត់ជាទង្វើសក្ការៈសំខាន់លើសទង្វើសក្ការៈឯទៀត ។ ស្វឡាត់ធ្វើឲ្យយើងចៀសចាកពីអំពើអាក្រក់ ហើយជួយយើងឲ្យមានជីវិតបរិសុទ្ធស្អាត ។

**ស៊្ឡាត់មានប៉ុន្មានប្រភេទ ?**



ស៊្ឡាត់ខាងក្រោមនេះជាស៊្ឡាត់វ៉ាយ៊ីប ។

១) ស៊្ឡាត់ប្រចាំថ្ងៃទាំង ៥ គឺ ៖

| | |
|---|---|
| ហ្វាច្ញ៉រ៍ | ២ រ៉ក់អាត់ ។ |
| ស៊ុហ្វូរ៍ | ៤ រ៉ក់អាត់ ។ |
| អាស្វ៉រ៍ | ៤ រ៉ក់អាត់ ។ |
| ម៉ាក់រីប | ៣ រ៉ក់អាត់ ។ |
| អ៊ីស្ហាអ៍ | ៤ រ៉ក់អាត់ ។ |

សរុប ១៧ រ៉ក់អាត់ ក្នុងមួយថ្ងៃ ។

២) ស៊្ឡាត់ អាយ៉ាស់ ។ ស៊្ឡាត់នេះអនុវត្តនៅពេលដែលមានខែឬថ្ងៃគ្រាស រញ្ជួយដី ឬ ព្រឹត្តិការណ៍ផ្សេងទៀតដែលធ្វើឲ្យនមុស្សភ័យរន្ធត់ ។
៣) ស៊្ឡាត់ម៉ាយិត ។ គឺស៊្ឡាត់ឲ្យអ្នកស្លាប់មុនបញ្ចុះសព ។

៤) ស៊្ឡាត់ក្រោយត៊្វ៉ាហ្វវ៉ាយ៊ីបនៅឯកាក់បាស់ ។

**មេរៀនទី ១៣**

# សំលៀកបំពាក់ស្ហ៏ឡាត់

ត្រូវអនុវត្តតាមលក្ខខណ្ឌខាងក្រោមនេះ ពាក់ព័ន្ធនឹងសំលៀកបំពាក់ ។

-សំលៀកបំពាក់ត្រូវត៏ហ្វៀរ (គឺបរិសុទ្ធ) ។

-សំលៀកបំពាក់ត្រូវមូបាស្ហ់ (គឺបានទទួលការអនញ្ញាត) ។

-មូបាស្ហ់មានន័យថា ឬមួយសំលៀកបំពាក់ជាកម្មសិទ្ធិរបស់អ្នកស្របតាមច្បាប់ ឬមួយអ្នកបានទទួលការអនុញ្ញាតពីម្ចាស់សំលៀកបំពាក់ហើយ ។

-សំលៀកបំពាក់ដែលគេទិញដោយប្រាក់ ដែលមិនបានបង់ស្ហ្ការកាត់និងឃុមស៍ (خمس) ទេនោះត្រូវចាត់ទុកថាក្ហ្ស៉ប៊ី (គឺមិនស្របតាមច្បាប់) ។ ក្ហ្ស៉ប៊ីផ្ទុយពីមូបាស្ហ់ ។ ដូច្នេះបំពេញស្ហ៏ឡាត់ជាមួយសំលៀកបំពាក់នេះ ត្រូវមោឃៈ



**មេរៀនទី ១២**

# ការរៀបចំខ្លួនបំពេញស្ហ៏ឡាត់

មុនចាប់ផ្ដើមបំពេញស្ហ៏ឡាត់ គេត្រូវរៀបចំខ្លួនជាមុនសិន ។ គេហៅការរៀបចំខ្លួននេះថា មូក្វទ្ទុំម៉ាត់ អ៊ុស្ហ-ស្ហ៏ឡាត់ ។

គេត្រូវរៀបចំខ្លួនដូចតទៅនេះគឺ៖

១. ត៏ហ្វារ៉ត់ (طهارة) - ខ្លួនយើងត្រូវស្អាត ។

២. វូឌ្ហ៊ុអ៍ត្រូវប្រើទឹកស្អាតនិងថ្លា ហើយមិនក្ហ្ស៉ប៊ី (បានមកដោយមិនត្រឹមត្រូវ) ។

៣. សំលៀកបំពាក់ត្រូវស្អាត មិនក្ហ្ស៉ប៊ី ហើយត្រូវគ្របជិតប៉ែកដែលត្រូវតែគ្របជិតក្នុងពេលស្ហ៏ឡាត់ ។

៤. ត្រូវពិនិត្យមើលទិសគ៊ីបឡាត់ឲ្យត្រឹមត្រូវ ។

៥. កន្លែង (និងកន្ទេល) ត្រូវតែស្អាតនិងមិនកុស្វប៊ី ។

៦. ត្រូវគោរពតាមពេលវេលា (គេមិនអាចបំពេញស្វ៍ឡាត់មុនពេលវេលាចូលមកដល់បានទេ) ។



## លំហាត់

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១. មូក្វដ្ជ័ដ្វាម៉ាត្ត អ៊ុស្វ-ស្វ៍ឡាត្តមានន័យថាអ្វី ?

២. ត្វ៍ហ្វារ៉ត្តមានន័យថាអ្វី ?

៣. ចូររាប់ឈ្មោះមូក្វដ្ជ័ដ្វាម៉ាត្ត អ៊ុស្វ-ស្វ៍ឡាត្តទាំងប្រាំមួយខដែលអ្នកបានសិក្សាខាងលើនេះ ហើយពន្យល់មូក្វដ្ជ័ដ្វាម៉ាត្ត អ៊ុស្វ-ស្វ៍ឡាត្តទាំងប្រាំមួយខនេះ ។

**មេរៀនទី ១៤**

# កន្លែងបំពេញស្ហ៍ឡាត់

សាសនាអ៊ីស្លាមបង្ហាត់បង្រៀនយើង ឲ្យចេះគោរពរបស់របរដែលជាកម្មសិទ្ធិរបស់អ្នកដទៃ មិនឲ្យយើងយករបស់នោះមកប្រើដោយឥតបានទទួលការអនុញ្ញាត ពីម្ចាស់របស់នោះទេ ។

ចូរគោរពតាមអនុសាសន៍ខាងលើនេះគ្រប់ពេលវេលា ជាពិសេសពេលអ្នកបំពេញស្ហ៍ឡាត់ ។

កន្លែងដែលអ្នកចង់ទៅបំពេញស្ហ៍ឡាត់ ត្រូវតែជាកន្លែងរបស់អ្នក ឬមួយអ្នកបានទទួលការអនុញ្ញាតពីម្ចាស់កន្លែងនោះរួចស្រេចហើយដើម្បីបំពេញស្ហ៍ឡាត់ ។

ប្រសិនបើកន្លែងនោះមិនមែនជាកន្លែងរបស់អ្នកទេ ហើយប្រសិនបើម្ចាស់កន្លែងនោះ មិនបាននុញ្ញាតឲ្យអ្នកប្រើកន្លែងនោះទេ ស្ហ៍ឡាត់របស់អ្នកនឹងមោឃៈ (បាទិ្ហល) ។



(បាទិ្ហល គឺមិនត្រឹមត្រូវទេ) ។

-សំលៀកបំពាក់ មិនត្រូវធ្វើមកពីប៉ែករបស់សត្វហ្ហារ៉ាំ ។ ឧទាហរណ៍ បំពេញស្ហ៍ឡាត់ជាមួយអាវដែលធ្វើអំពីរោមតោ មិនសមស្របតាមច្បាប់ទេ ។

-សំលៀកបំពាក់ធ្វើអំពីប៉ែកសត្វហ្ហាឡាល់ ដែលត្រូវសំឡែះស្របតាមច្បាប់អ៊ីស្លាមអនុញ្ញាតឲ្យប្រើបាន ។

-សំលៀកបំពាក់ធ្វើអំពីប៉ែកសត្វហ្ហាឡាល់ ដែលស្លាប់ខ្លួនឯង ឬត្រូវសំឡែះក្រៅច្បាប់អ៊ីស្លាមមានពីរករណីគឺៈ

ក) បើប៉ែកសត្វនោះជាប៉ែកមានជីវិត (ដូចជា ខ្លាញ់ សាច់ ស្បែក... ជាដើម) មិនអនុញ្ញាតឲ្យបំពេញស្ហ៍ឡាត់ជាមួយសំលៀកបំពាក់នោះទេ ។

ខ) បើប៉ែកសត្វនោះជាប៉ែកគ្មានជីវិត (ដូចជា រោម ស្នែង ធ្មេញ ក្រចក... ជាដើម) គេអនុញ្ញាតឲ្យបំពេញស្ហ៍ឡាត់ជាមួយសំលៀកបំពាក់នោះបាន ។

**សម្រាប់តែបុរស**

-សំលៀកបំពាក់មិនត្រូវធ្វើអំពីមាសទេ ទោះជាមាសសុទ្ធក្តី មាសលាយក្តី ។ បុរសត្រូវហាមពាក់មាសគ្រប់ពេល មិនត្រឹមតែក្នុងពេលបំពេញស្វ៍ឡាត់ប៉ុណ្ណោះទេ ។

-សំលៀកបំពាក់មិនត្រូវធ្វើអំពីសូត្រសុទ្ធទេ ។ បុរសត្រូវហាមពាក់សូត្រសុទ្ធគ្រប់ពេល មិនត្រឹមតែក្នុងពេលបំពេញស្វ៍ឡាត់ប៉ុណ្ណោះទេ ។



**លំហាត់**

១. ត៌ហ្វៀរមានន័យថាអ្វី ?

២. មូបាស្ស៊់មានន័យថាអ្វី ?

៣. កុស្វ៉ប៊ីមានន័យថាអ្វី ?

៤. ប្រសិនបើសំលៀកបំពាក់ ដែលអ្នកស្លៀកពាក់ក្នុងស្វ៍ឡាត់ធ្វើអំពីប៉ែកសត្វ តើអ្នកត្រូវប្រយ័តអ្វីខ្លះ ?

៥. សំលៀកបំពាក់ប្រភេទណា ដែលត្រូវហាមសម្រាប់បុរសជាពិសេសក្នុងពេលបំពេញស្វ៍ឡាត់ តែអនុញ្ញាតសម្រាប់ស្ត្រី ?

| ឈ្មោះស្ហ៏ឡាត់ | ពេលហ្វាឌ្ហីឡាត់ | ពេលក្ហ៏ឌ្ហ៏ |
|---|---|---|
| ហ្វាជ្ញ់រ៍ (ស៊្ហុបហ៊ា៍) | ចាប់ផ្ដើមពីពេល ស៊្ហុបហ៊ា៍ ស្ហ៏ឌ្ហិក្ហ (មុនថ្ងៃរះ) | ពេលថ្ងៃរះ |
| ស៊្ហុហ្ស៍រ៍ (កណ្ដាលថ្ងៃ) | ចាប់ផ្ដើមពីពាក់កណ្ដាលថ្ងៃ | ពេលថ្ងៃលិច |
| អ៊្ហាស្ហ៍រ៍ | ក្រោយស្ហ៏ឡាត់ស៊្ហុហ្ស៍រ៍ | ពេលថ្ងៃលិច |
| ម៉ាក់្ហរីប (ក្បាលព្រលប់) | ក្រោយថ្ងៃលិច | កណ្ដាលយប់អធ្រាត្រ |
| អ៊្ហីស្ហាអ៍ | ក្រោយស្ហ៏ឡាត់ម៉ាក់្ហរីប | កណ្ដាលយប់អធ្រាត្រ |



ប្រសិនបើអ្នកទៅឯម៉ាស់យ៊្ជិដ្ធ អ្នកមិនបាច់សូមអនុញ្ញាតពីអ្នកណាទេ ។ ហេតុអ្វី ? ពីព្រោះម៉ាស់យ៊្ជិដ្ធជាគ្រឹះដ្ឋានរបស់អល់ឡោះហ្វ៍﷿ ដែលត្រូវសាងសង់ឡើងដើម្បីបំពេញស្ហ៏ឡាត់ ។

គួររំលឹកផងដែរថា អល់ឡោះហ្វ៍﷿ចង់ឲ្យយើងបំពេញស្ហ៏ឡាត់លើកន្លែងស្អាត ។ ដូច្នេះចូរធ្វើយ៉ាងណាដើម្បីឲ្យបន្ទប់អ្នកស្អាតនិងបរិសុទ្ធ (គឺត៏្ហហ្វៀរ) ។

បើអ្នកមានកម្រាលសម្រាប់ស្ហ៏ឡាត់ក្នុងបន្ទប់អ្នក ចូរបត់វាទុកក្រោយពីបានបំពេញស្ហ៏ឡាត់រួច ហើយចូរទុកនៅឯកន្លែងស្អាតនិងត៏្ហហ្វៀរ ។

**ម៉ាស់យ៊្ជិដ្ធជាគេហដ្ឋានរបស់អល់ឡោះហ្វ៍**
**ដែលបានសាងសង់ឡើងដើម្បីស្ហ៏ឡាត់**

## លំហាត់

១. តើសាសនាអ៊ីស្លាមបង្គាប់បង្រៀនយើងអ្វីខ្លះ ទាក់ទងនឹងកម្មសិទ្ធិរបស់អ្នកដទៃ ?
២. ទាក់ទងនឹងកន្លែងដែលអ្នកបំពេញស៏ឡាត់ តើចាំបាច់មានលក្ខខណ្ឌអ្វីខ្លះ ?
៣. តើលក្ខខណ្ឌទាំងនេះ ពាក់ព័ន្ធនឹងម៉ាស់យ៉ិដ្វដែរទេ ។ ហេតុអ្វី ?
៤. តើម៉ាស់យ៉ិដ្វជាអ្វី ? តើអ្វីទៅគោលដៅរបស់ម៉ាស់យ៉ិដ្វ ?
៥. ហេតុអ្វីអ្នកចាំបាច់ត្រូវថែរក្សាបន្ទប់អ្នកឲ្យស្អាត និង ត៏ហ្វៀរ ?



## មេរៀនទី ១៥

# ពេលស៏ឡាត់

ប្រសើរបំផុតគឺស៏ឡាត់ទាន់ពេលវេលា (គឺពេលហ្វាឌ៏ឡាត់ ពេលដែលស៏ឡាត់មានមគ្គផលល្អបំផុត) ។ បំពេញស៏ឡាត់ក្នុងពេលនេះទទួលបាននូវផល(ស្វាវ៉ាប់)ច្រើនជាងគេ ។

ឧស្សាហ៍បំពេញស៏ឡាត់ទាន់ពេលកំណត់ ធ្វើឲ្យយើងមានស្មារតីទៀងទាត់ពេលប្រសើរឡើង ។

កាលណាអំឡុងពេលស៏ឡាត់ចប់ ស៏ឡាត់នោះទៅជាស៏ឡាត់ក៏ដ៏ (قَضى) ។ ប្រសិនបើអ្នកមិនបានបំពេញស៏ឡាត់មុនពេលដែលវាទៅជាក៏ដ៏ទេ អ្នកត្រូវបំពេញស៏ឡាត់ដោយនៀតថាក៏ដ៏ (ជូសវ៉ាយ៉ិប) ។

បណ្តែតបណ្តោយស៏ឡាត់វ៉ាយ៉ិប ឬខានបំពេញស៏ឡាត់វ៉ាយ៉ិប ទាល់តែធ្វើឲ្យវាទៅជាក៏ដ៏នោះធ្វើឲ្យខូចប្រយោជន៍ និងមានទណ្ឌកម្មធ្ងន់ ។

ជាមួយទឹកពីរដង (យកល្អបីដង) ។

ហាមបត់ជើងតូចឈរ ។ ធ្វើបែបនេះនឹងទទួលរងនូវទណ្ឌកម្មធ្ងន់ក្រោយពីស្លាប់ ។

ក្រោយពីបានបត់ជើងធំហើយ ត្រូវសម្អាតប៉ែកអវយវៈនោះដោយទឹក ដោយក្រណាត់ ឬ ក្រដាស់ ដោយមានលក្ខខណ្ឌថាក្រណាត់ឬប្រដាសនោះត្រូវហ្វៀរ (បរិសុទ្ធតាមច្បាប់សាសនា) ហើយស្ងួត ។

វ៉ាយ៉ីបត្រូវប្រើបីកំណាត់ (ក្រណាត់ឬក្រដាស) ទោះបីប៉ែកអវយៈនោះស្អាតមុនហើយក៏ដោយ ។ ប្រសិនបើក្រោយពីបានប្រើបីកំណាត់ហើយ ប៉ែកអវយវៈនោះនៅតែមិនស្អាត ឲ្យប្រើច្រើនកំណាត់ថែមទៀត ទាល់តែស្អាត ។



## លំហាត់

១. តើពេលហ្វាឌីឡាត់មានន័យថាអ្វី ?

២. ពេលណាទៅស្វ៍ឡាត់ទៅជាស្វ៍ឡាត់ក៏ដ្ឋ៍ តើអ្នកត្រូវធ្វើយ៉ាងណាបើវាទៅជាក៏ដ្ឋ៍នោះ ?

## មេរៀនទី ១៦

# ណាយ៉ាសាស់ (نجسة)

ណាយ៉ាសាស់ គឺវត្ថុដែលស្ហារីអាស់ចាត់ទុកថាមិនបរិសុទ្ធ (គឺមិនបរិសុទ្ធយោលតាមច្បាប់សាសនា) ។

ណាយ៉ាសាស់គឺវត្ថុដែលមានធាតុដើមមិនបរិសុទ្ធ ហើយធ្វើឲ្យវត្ថុដទៃទៅជាមិនបរិសុទ្ធដោយការប៉ះពាល់ ។

វត្ថុនីមួយទៅជាណាយ៉ីស (គឺមិនបរិសុទ្ធ) ប្រសិនបើវាទៅប៉ះវត្ថុមួយទៀតដែលណាយ៉ីស បើវត្ថុណាមួយក្នុងចំណោមវត្ថុទាំងពីរនេះទទឹក ឬក៏វត្ថុទាំងពីរនេះទទឹក ។

ដូច្នេះ វត្ថុណាយ៉ីសដែលស្ងួតមិនអាចធ្វើឲ្យវត្ថុដទៃទៅជាណាយ៉ីសដែរបានទេដោយការប៉ះពាល់ ។

**ប្រភេទណាយ៉ាសាស់**



វត្ថុខាងក្រោមនេះជាណាយ៉ីសតាំងពីធាតុដើមមកម្ល៉េះ គឺ៖

-ទឹកនោម
-លាមក (អាចម៍)
-ឈាម
-សាកសព (ខ្មោច)
-ឆ្កែ
-ជ្រូក
-កាហ្វៀរ
-សុរា
-ប៊ីយ៉ែរ (ហ្វុក្ខក៏)

**ច្បាប់ទាក់ទងនឹងទីបន្ទោបង់**

ត្រូវចូលទៅក្នុងទីបន្ទោបង់ដោយឈានជើងឆ្វេង ។

ហាមអង្គុយបែរមុខឬបែរខ្នងដាក់គីបឡាត់ (បើទីបន្ទោបង់អ្នកបែរមុខទៅរកគីបឡាត់ ចូរអ្នកអង្គុយឆៀងបន្តិច) ។

ក្រោយពីបត់ជើងតូចរួច ចាំបាច់ត្រូវលាងប៉ែកអវយវៈនោះ

## លំហាត់

១. អ្វីទៅមុច្ចតាហ្វ៊ីដ្វ ?

២. តាក់វ្លីដ្វមានន័យថាអ្វី វាទៅជាវ៉ាយ៉ិបពេលណា ?

៣. មូក្វល់លីដ្វមានន័យថាអ្វី ?

៤. ប៊្វលុក្កមានន័យថាអ្វី  ពេលណាទៅប្រុសៗនិងស្រីៗដល់ប៊្វលុក្វ ?

៥. តើអ្នកនៅក្នុងតាក់វ្លីដ្វរបស់អ្នកណា ?



## លំហាត់

១. តើណាយ៉ាសាស្វមានន័យថាអ្វី ?  តើវាធ្វើឲ្យវត្ថុដទៃទៅណាយ៉ិសដូចម្ដេចទៅ ?

២. ចូររៀបរាប់ប្រភេទណាយ៉ាសាស្វដែលអ្នកស្គាល់ ។

៣. ទាក់ទងនឹងទីបន្ទោបង់ តើអ្វីទៅដែលហ្វារ៉ាំ ?

៤. តើអ្នកត្រូវសម្អាតដោយអ្វីទៅ  បន្ទាប់ពីបត់ជើងតូចរួចប៉ុន្មានដង ?

៥. តើអ្នកត្រូវសម្អាតដោយអ្វីទៅ  បន្ទាប់ពីបត់ជើងធំរួចប៉ុន្មានដង ?

## មេរៀនទី ១៧

# តាក់លីដ្ង

ក្នុងវិស័យជីវិតនីមួយៗ យើងត្រូវការអ្នកជំនាញដែលចេះគ្រប់គ្រងវិស័យនោះ ។

ក្នុងទស្សនវិស័យនេះដែរ ពាក់ព័ន្ធនឹងរឿងច្បាប់អ៊ីស្លាម យើងត្រូវគោរព តាមវិន័យរបស់អ្នកជំនាញខាងច្បាប់ទាំងនេះ ។

គេហៅអ្នកជំនាញទាំងនេះថា មុចូតាហ្វ៊ីដ្ង (مجتهد) ឯការគោរពតាមវិន័យទាំងនេះ គេហៅថា តាក់លីដ្ង (تقليد) ។

រាល់គ្នា ប្រុសឬស្រី ដែលគ្រប់អាយុ (បាលីក៊ុ) ត្រូវអនុវត្តតាមវិន័យទាំងនេះអាស្រ័យ ហ្វ៊ូរូអ៊ុដ្ឌីន (فروع الدين) ។

តាក់លីដ្ងមានន័យថា គោរពច្បាប់អ៊ីស្លាមតាមវិន័យដែលមុចូតាហ្វ៊ីដ្ង (مجتهد) បានចែង ។



អ្នកដែលប្រតិបត្តិតាមវិន័យរបស់មុចូតាហ្វ៊ីដ្ង (مجتهد) គេហៅថា មូក្កល់លីដ្ង ។

ពេលនេះយើងនៅក្នុងតាក់លីដ្ងរបស់ អាយ៉ាទុលឡោះហ្វ៍ អាល់-អ៊ុស្ម៉ា សៃយីដ្ង អ៊ុលី អាល់-ហ៊ូសៃនី អាស់-ស៊ីសតានី (ណាយ៉ាហ្វ់ អ៊ីរ៉ក៊ូ) ។

កាលណាគេបានដល់ប៊ូលុក៊ុ (بلوغ គ្រប់អាយុ បាលីក៊ុ) គេត្រូវនៀតថា នឹងតាមការវិនិច្ឆ័យរបស់អាយ៉ាទុលឡោះហ្វ៍មួយក្នុងការប្រតិបត្តិសាសនា ។

**ប៊ូលុក៊ុ** (بلوغ)

ស្រីៗដល់ប៊ូលុក៊ុ (បាលីក៊ុ គឺគ្រប់អាយុ) ពេលមានអាយុ ៩ ឆ្នាំយោលតាមសាសនាអ៊ីស្លាម (តាមប្រក្រតិទិនចន្ទ្រគតិ) ។ ដូច្នេះពួកនាងត្រូវអនុវត្តតាមវ៉ាយ៉ីបទាំងអស់ ។ ប្រុសៗដល់ប៊ូលុក៊ុពេលមានអាយុ ១៥ ឆ្នាំពេញ ។

**៦) តាស់ប៊ិះហ្វ៍**

ក្រោយពីស្វឡាត់ភ្លាម មុសតាហ្ពាប់ (ស៊ូណាត់) ឲ្យសូត្រតាស់ប៊ិះហ្វ៍ហ្វាទីម៉ាស់ដូចតទៅគឺ ៖

អល់ឡ៉ហ្វ អាក់បារ (អល់ឡោះហ្វ៍មហាធំ ៣៤ ដង ថ្កើងបំផុត)
អាល់ហ្ពាំឌូលិលឡាស់ (អល់ឡោះហ្វ៍ជាទី ៣៣ ដង សើ្វចសរសើរ)
ស៊ុបហ្ពាណល់ឡោះហ្វ៍ (អល់ឡោះហ្វ៍មហា ៣៣ ដង រុងរឿង)

**៧) ទេវតា**

ទេវតាមានចំនួនច្រើន ហើយមើលមិនឃើញទេ។ ទេវតាបំពេញភារកិច្ចច្រើនរាប់មិនអស់ ដែលអល់ឡោះហ្វ៍ដាក់មកលើអស់ព្រះអង្គ។ អស់ទេវតាថ្វាយសេចក្ដីសើ្វចសរសើរចំពោះអល់ឡោះហ្វ៍និងគោរពព្រះបញ្ជាព្រះអង្គ។ ទេវតាមួយចំនួនរ៉ូគុអ៊ូនៅឯឋានសួគ៌ ទេវតាឯទៀតស៊ូឃ្លូដ រីឯទេវតាមួយចំនួនទៀតធ្វើសក្ការបូជាអល់ឡោះហ្វ៍ រៀងរហូត



**មេរៀនទី ១៨**

# សាឡើងវិញ

**១) អល់ឡោះហ្វ៍**

រាល់ពេលដែលយើងថា "អល់ឡោះហ្វ៍" យើងត្រូវថាបន្ថែមថា "ស៊ុបហ្ពាណាហ៊ូ វ៉ា តាអាឡា"។

**២) ព្រះសាស្ដា**

ក) អល់ឡោះហ្វ៍ عز وجل បានចាត់បញ្ជូនមក ១២៤០០០ ព្រះសាស្ដា عليهم السلام។ ព្រះសាស្ដា عليهم السلام ទាំងអស់នេះសុទ្ធតែត្រឹមត្រូវតាមសច្ចធម៌។

ខ) ព្រះសាស្ដាមុនគេបង្អស់គឺអាដាំ عليه السلام។ ព្រះសាស្ដាចុងក្រោយបង្អស់គឺមូហាំម៉ាដ់ មុស្ទហ្វា صلى الله عليه وآله وسلم។

**៣) ព្រះសាស្ដាអ៊ូលុល-អាស់ម៍** (أولوالعزم)

អ៊ូលុល-អាស្ម៍ គឺព្រះសាស្តាធំថ្កើង មាន ៥ អង្គគឺ ៖

- **ព្រះសាស្តា នុះហ៍ؑ ។**
- **ព្រះសាស្តា អ៊ិបរ៉ហ៊ីមؑ ។**
- **ព្រះសាស្តា មូសាؑ ។**
- **ព្រះសាស្តា អ៊ីសាؑ ។**
- **ព្រះសាស្តា មូហាំម៉ាដ់ មុស្តហ្វាﷺ ។**

**៤) ព្រះគម្ពីរ**

ព្រះគម្ពីរត្រូវបើកឲ្យដឹងដូចតទៅគឺ ៖

ព្រះគម្ពីរតៅរ៉ត្ត ត្រូវបើកឲ្យព្រះសាស្តាមូសាؑដឹង ។
ព្រះគម្ពីរស៊ាប៊ូរ ត្រូវបើកឲ្យព្រះសាស្តាដាវូដؑដឹង ។
ព្រះគម្ពីរអ៊ីនយ៉ីល ត្រូវបើកឲ្យព្រះសាស្តាអ៊ីសាؑដឹង ។
ព្រះគម្ពីរគួរអានត្រូវបើក ឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺយើង ដឹង ។

**៥) អាស្ហលុល-បៃត៍**



អាស្ហលុល-បៃត៍មាន ១៤ អង្គគឺ ៖

ព្រះសាស្តាមូហាំម៉ាដ់ﷺយើង ហ្វាទីម៉ាស្ហ់ អាស់-ស៊ាស្ហ់រ៉ អ៊ ﴿سلام الله عليها﴾ ព្រះរាជបុត្រីរបស់ព្រះអង្គﷺ និងអ៊ីម៉ាំ(عليهم السلام)ទាំង ១២ អង្គ ។

តើអ្នកស្គាល់ឈ្មោះអ៊ីម៉ាំ(عليهم السلام)យើងទាំង ១២ អង្គទេ ?
ពេលគេថាឈ្មោះអ៊ីម៉ាំយើងអង្គណាមួយ យើងត្រូវថា "អ៊ាឡៃហ៊ី អាឡាម" ។
ពេលគេថាឈ្មោះប៊ីប៊ីហ្វាទីម៉ាស្ហ់ យើងត្រូវថា "អ៊ាឡៃហ្វា សាឡាម" ។

ពេលថាឈ្មោះអាស្ហលុល-បៃត៍ យើងត្រូវឱនក្បាលដើម្បីសម្តែងសេចក្តីគោរព ហើយត្រូវសូត្រស៊្វឡាវ៉ាត ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថា៖ "អ្នកណាមិនសូត្រស៊្វឡាវ៉ាត បន្ទាប់ពីបានថា ឬបានឮឈ្មោះអាស្ហលុល-បៃត៍អង្គណាមួយទេ អ្នកនោះជាបុគ្គលកំណាញ់ ។"

៨. ចូរឲ្យព្រះនាមអគ្គទេវតាទាំងបួនអង្គ ។ តើទេវតាទាំងនេះមានមុខងារអ្វី ?

៩. តើទេវតាកត់ទង្វើល្អរបស់យើងមានព្រះនាមអ្វី ?

១០. តើទេវតាកត់ទង្វើអាក្រក់របស់យើងមានព្រះនាមអ្វី ?



លុះដល់ថ្ងៃជំនុំជម្រះ ។

ទេវតាបួនអង្គ ក្នុងចំណោមទេវតាទាំងនេះ ដែលគេស្គាល់ជាងគេគឺ៖

**យ៉ីប់រ៉អ៊ីល**عليه السلام-ទេវតាដែលនាំព្រះបញ្ញា និងព្រះរាជសាររបស់អល់ឡោះហ្វ៍មកឲ្យព្រះសាស្តា ។ ព្រះអង្គعليه السلامនាំអាយ៉ាត់គូរអានមកឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺ ។

**មីកាអ៊ីល**عليه السلام-ទេវតាដែលចែកគ្រឿងទ្រទ្រង់ជីវិត ឲ្យយើង (រីស្គី) ពោលគឺ អាហារ សំលៀកបំពាក់និងជម្រក ។ អល់ឡោះហ្វ៍ប្រទានឲ្យយើងនូវរបស់ចាំបាច់សម្រាប់ជីវិត ។

**អ៊ីស្រ៉ហ្វីល**عليه السلام-ទេវតាដែលនឹងផ្លុំស្នែងមុនគីយ៉ាម៉ាត់ និងដែលធ្វើឲ្យអ្វីៗដែលមានជីវិតវិនាស ។ ព្រះអង្គعليه السلامនឹងផ្លុំស្នែងលើកទីពីរ ដើម្បីធ្វើឲ្យអ្នកស្លាប់ទាំងអស់រស់ឡើងវិញ ។ បន្ទាប់ពីនោះគឺថ្ងៃជំនុំជម្រះ (គីយ៉ាម៉ាត់) ។

**អ៊ីស្ររ៉អ៊ីល**عليه السلام-ទេវតាដែលដកព្រលឹងមនុស្ស ។ គេស្គាល់ព្រះនាមរបស់ទេវតាអង្គនេះជាងគេថា "មច្ចុរាជ" (ទេវតានៃ

សេចក្តីស្លាប់ ملك الموت) ។

ក្រៅពីអគ្គទេវតាទាំងបួនអង្គនេះ មានទេវតាច្រើនអង្គទៀត គឺ ៖

**រ៉គីប**ﷺ-ទេវតាដែលកត់អំពើល្អរបស់យើងទុក ។ ទេវតាអង្គនេះនៅលើស្មាស្តាំយើង ។

**អ៊ាទីដ្វ**ﷺ-ទេវតាដែលកត់អំពើអាក្រក់ របស់យើងទុក ។ ទេវតាអង្គនេះនៅលើស្មាឆ្វេងយើង ។

ទេវតាទាំងនេះមាននាទីកត់ទង្វើទាំងអស់របស់យើង នៅក្នុងបញ្ជី ។ បញ្ជីទាំងនេះមានមុខងាររំលឹកឡើងវិញទង្វើល្អ និងទង្វើអាក្រក់របស់យើងក្នុងថ្ងៃគ្វីយ៉ាម៉ាត្ទ៉ ។ ដូច្នេះ ទោះបីយើងបានភ្លេចទង្វើរបស់យើងក៏ដោយ ទេវតាទាំងនេះនឹងមិនភ្លេចកត់ទុកទង្វើទាំងនេះក្នុងបញ្ជីនោះទេ ។



## លំហាត់

១. តើអ្នកត្រូវសូត្រអ្វីក្រោយពីបានថា "អល់ឡោះហ្វ៍" ?

២. តើប៉ុន្មានព្រះសាស្តា ដែលត្រូវចាត់បញ្ជូនមកបង្ហាត់បង្រៀនយើង ? ព្រះសាស្តាណាជាព្រះសាស្តាមុនគេបង្អស់ ? ព្រះសាស្តាណាជាព្រះសាស្តាក្រោយគេបង្អស់ ?

៣. តើអ៊្វលុល-អ៊ុាស្ស៊ុម៍មានន័យថាអ្វី ? ចូររាប់ឈ្មោះអ៊្វលុល-អ៊ុាស្ស៊ុម៍ទាំងនោះ ?

៤. ចូររាប់ឈ្មោះព្រះគម្ពីរ តើព្រះគម្ពីរទាំងនេះត្រូវដាក់មកឲ្យអ្នកណាខ្លះ ។

៥. ចូរឲ្យព្រះនាមរបស់អាស្ម៉ លុល-ហ៊ៃត៍ទាំងអស់ ។

៦. តើអ្នកត្រូវសូត្រអ្វី ក្រោយពីបានថាព្រះនាមរបស់អាស្ម៉ លុល-ហ៊ៃត៍ ?

៧. តើសូត្រអ្វីខ្លះក្នុងតាស់ប៊ិះហ្វ៍ហ្វាទីម៉ាស្ទ៉ ? ប៉ុន្មានដង ?

## លំហាត់

១. ចូរសរសេរ ១០ ខ ដែលជាវ៉ាយ៉ូបក្នុងស្វ៍ឡាត្ទ់ ដោយអធិប្បាយខនីមួយៗ ។

២. តើរុកន៍មានន័យថាអ្វី ?

៣. តើកុយ៉រ៉ រុកនីមានន័យថាអ្វី ?

៤. ស្វ៍ឡាត្ទ់ប្រៀបបាននឹងសំណង់ដូចម្ដេចទៅ ? ចូរអធិប្បាយដោយសំអាងលើរុកន៍ និង កុយ៉រ៉ រុកនី ។

កំណែលើកទី ២, 06/2020



## មេរៀនទី ១៩

# ទង្វើវ៉ាយ៉ីបក្នុងស្វ៍ឡាត្ទ់

(រុកន៍ (ركن) និង កុយ៉រ៉ រុកនី)

អ្នកដឹងស្រាប់ហើយថាក្នុងស្វ៍ឡាត្ទ់មានច្រើនប៉ែក ។ ក្នុងមេរៀននេះអ្នកនឹងបានដឹងនូវតារាងទង្វើវ៉ាយ៉ីបក្នុងស្វ៍ឡាត្ទ់ ។

ក្នុងស្វ៍ឡាត្ទ់មានខវ៉ាយ៉ីប ១០ ខ គឺ ៖

**១. នៀត**

បំណងបំពេញស្វ៍ឡាត្ទ់ "គ្ហូរបាតាន់ អ៊ីលឡ្មុលឡោះហ្វ" ។

**២. តាក់បីរ៉ទុល អិះហ្រ៉ាម**

"អល់ឡ៉ហ្វូ អាក្ពុបារ" ទី ១ ។

**៣. គ្ហីយ៉ាម**

ឈរស្មូត្រ

**៤. គ៏រ៉អ៊ាត់** (قراءات)
សូត្រក្នុងគ៏យ៉ាម

**៥. រូគុអ៊ុ**
បង្អោនខ្លួន

**៦. សាច់ដ្វាស់ទាំងពីរ**
ក្រាបប្រណិប័តន៍ ។ ថ្ងាស ជង្គង់ បាតដៃទាំងពីរ មេជើង ប៉ះផ្ទៃកម្រាល ។

**៧. ស៊ីក៍រ (ឬ ស៊ីកៀរ)**
សូត្រក្នុងគ៏យ៉ាមនិងក្នុងសាច់ដ្វាស់ ។

**៨. តាស្ហាស់ហ៊្វូដ**

**៩. សាឡាម**

**១០. តារទីប** (ترتيب) **និង មូវ៉ាឡាត់**
ស្វ៍ឡាត់ប្រៀបបាននឹងសំណង់ដែលមានច្រើនប៉ែក ។ ប៉ែកមួយចំនួនជាគ្រឹះរបស់សំណង់ ឯមួយចំនួនទៀតនៅពីលើ



គ្រឹះ ។ ប្រសិនបើគ្រឹះមិនមាំទេ សំណង់នឹងរលំ ។

ដូចគ្នាដែរ ទង្វើវ៉ាយ៊ីបក្នុងស្វ៍ឡាត់បែងចែកជាពីរប្រភេទគឺៈ **រុកន៍** (រ៉ូកុន) និង **កុយ៉រ៉ រុកនី** (មានន័យថា មិនមែនរ៉ូកុនដាច់ខាតខានមិនបាននោះទេ ពោលគឺ ជារ៉ូកុនអនុលោម) ។

**រុកន៍** (រ៉ូកុន) ជាប៉ែកនានារបស់ស្វ៍ឡាត់ដែលជាគ្រឹះ (គឺជាវ៉ាយ៊ីបខានមិនបានជាដាច់ខាត) ។
**កុយ៉រ៉ រុកនី**ជាប៉ែកនានាដែលមិនមែនជាប៉ែករបស់គ្រឹះទេ (មិនមែនជាវ៉ាយ៊ីប ខានមិនបានជាដាច់ខាតនោះទេ ពោលគឺ ជារ៉ូកុនអនុលោម) ។